ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

បណ្ណាល័យ
ពុទ្ធិ
LIBRARY
BUDDHIST INSTITUTE

និរាសនគរវត្ត


ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

៣១៥.
៣៨៤

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៤១

ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
ពុទ្ធសាសនបណ្ឌិត្យ និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
អង្គការរីហ្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ
ករុណាខ្មែរ និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

៣១៩.៣៥៤

ពាក្យកាព្យ

និរាសនគរវត្ត

ឧកញ៉ាសុត្តន្តប្រីជា **ឥន្ទ**
រៀបរៀង

បោះពុម្ពគ្រាទី ២ ចំនួន ២.០០០ ច្បាប់
ដោយថតចម្លងតាមច្បាប់បោះពុម្ពគ្រាទី ១ ឆ្នាំ ១៩៦៩

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

៣៣៤០/៩៧

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៤១ គ.ស ១៩៩៧

UN PELERINAGE A ANGKOR

Poème composé par

OKNHA SUTTANTAPRIJÃ IN

Deuxième Edition

2.000 Ex.

PHNOM PENH

Edition de l'Institut Bouddhique

1997

សេចក្តីបញ្ជាក់
ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ « **និរាសនគរវត្ត** » នេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយបានទទួលការឧបត្ថម្ភពីអង្គការជំនួយសូត្វស៊ូជប៉ុន (JSRC) និងពីក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ។

ពុទ្ធសាសនបណ្ឌិត្យ ទុកឱកាសជូនអ្នកអានពិនិត្យ សិក្សាដោយខ្លួនឯងនូវទេពកោសល្យនៃអ្នកនិពន្ធពាក្យកាព្យនិរាសនគរវត្ត ដែលត្រូវបានបោះពុម្ពឡើងវិញនាពេលនេះ ។

គោលបំណងនៃកាបោះពុម្ពឡើងវិញនៃសៀវភៅនេះ គឺ :

- ដើម្បីថែរក្សាទុកឱ្យបន្តគង់វង្សនូវស្នាដៃអក្សរសិល្ប៍របស់ខ្មែរពីបុរាណ កុំឱ្យបាត់បង់ ។
- ដើម្បីទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយបានស្គាល់ បានសិក្សារៀនសូត្រ ។
- ដើម្បីទុកឱ្យអ្នកតែងនិពន្ធក្រោយៗ បានសិក្សាប្រៀបធៀបស្នាដៃរបស់ខ្លួន ។

វីការបោះពុម្ពឡើងវិញលើកនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

ភ្នំពេញ, ខែ កក្កដា ឆ្នាំ ១៩៩៧

ពុទ្ធសាសនបណ្ឌិត្យ

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) និងដោយមានការឧបត្ថម្ភពី

ក្រុមប្រឹក្សាពិភពលោក ស្តីពីសាសនា និងសន្តិភាព (WCRP)

យើងអធិដ្ឋាន សូមអោយសៀវភៅនេះបានជាវិភាគទានរក្សាមិត្តភាព ជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee (JSRC) with the contribution from

The Japanese Committee of the World

Conference on Religion and Peace (WCRP)

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.

អារម្ភកថា

ពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយអត្ថបទ "ពាក្យកាព្យនិរាសនគរវត្ត" នេះ រួចម្ដងមកហើយ គឺផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៣៤ លេខ ៧-៨-៩ ។ កាលគ្រានោះ អ្នកនិពន្ធនៃពាក្យកាព្យ បានយកសំណៅមកប្រគល់ឲ្យពុទ្ធសាសនបណ្ឌិត្យ ចុះផ្សាយ ដោយលោកជាអ្នកពេញចិត្តក្រៃលែងចំពោះអក្សរសាស្ត្រ ។ យើងក៏សូមថ្លែងអំណរដ៏លើសលុបចំពោះកវីរូបនេះផង ។

ពពួកអ្នកសិក្សាស្រាវជ្រាវ និងអ្នកនិយមពាក្យកាព្យឃ្លោងដែលធ្លាប់អាន ធ្លាប់សិក្សាអត្ថបទនេះ ជាច្រើននាក់ បានមកសុំឲ្យយើងចាត់ចែងយកមកបោះពុម្ពសាឡើងជាថ្មីម្ដងទៀត ធ្វើជាសៀវភៅមួយដោយឡែក ។ យើងក៏ចាត់លោក **លី.ធាមតេង** អ្នកស្រាវជ្រាវប្រចាំវិជ្ជាឋានយើង ឲ្យរើអត្ថបទនេះមកផ្ទៀងផ្ទាត់សេចក្ដី និងតម្រូវអក្ខរាវិរុទ្ធដែលភ្លាំងភ្លាត់ កាលបោះពុម្ពលើកមុន ឲ្យបានត្រឹមត្រូវ ហើយនិងធ្វើនយលក្ខណៈខ្លះពន្យល់ពាក្យណាដែលពិបាក ៗ ដូចជាពាក្យដែលគេធ្លាប់ប្រើតែកាលពីសម័យនោះ, ពាក្យខ្លះក្លាយមកពីភាសាបរទេស និងពាក្យខ្លះទៀតជាសំដីអ្នកស្រុកនៅភូមិភាគបាត់ដំបង · សៀមរាប · ហើយដែលអ្នកខេត្តដទៃទៀត

ពុំសូវស្តាប់ឮ ។ ការបន្ថែមនយលក្ខណៈបែបនេះ ដើម្បីជួយសម្រួលអ្នកអានទូទៅ ជាពិសេសអ្នកសិក្សាដែលមានវ័យនៅក្មេង ៗ ឲ្យបានងាយយល់អាចឈោងចាប់ន័យនិងរសខ្លឹមសារ ក្នុងពាក្យកាព្យនេះ បានច្បាស់លាស់ ។ ប៉ុន្តែទោះបីជាខំយ៉ាងនេះក្តី ក៏គង់នៅមានខ្វះចន្លោះច្រើនទៀតមិនខាន យើងក៏សុំអភ័យទោសចំពោះលោកអ្នកអាន អំពីការខ្វះខាតភ្លាំងភ្លាត់ខ្វះក្រៅចេតនានេះ ផងដែរ ។

គោលបំណងធំរបស់យើង គឺការបំផុសនូវពាក្យកាព្យ និង ធ្វើឲ្យលេចភ្លឺត្រចះត្រចង់ឡើងនូវសម្ផស្សកាព្យ សំនួនវោហារ ព្រមទាំងអត្ថរសជាខ្លឹមសារ ដែលកវីបានបង្កប់នៅលាយឡំក្នុងអត្ថបទនេះ, ព្រោះជារបស់ល្អយ៉ាងណាក៏ដោយ បើគេពុំបានលាតត្រដាងឲ្យឃើញរូបឆោមទេ ស្ថិតនៅលាក់ខ្លួនដោយគៀនគោះ, របស់នោះឯងក៏ពុំមានប្រយោជន៍អ្វីឡើយ ហើយជាការឥតអំពើថែមទៀត ។ ដូច្នេះ យើងត្រូវតែព្យាយាមលើកយកមកផ្សាយជាសាធារណៈ ទើបបានជាការសិក្សា យកជាបទពិចារណា បង្កើនស្មារតីចេះដឹង ឲ្យកាន់តែបរិបូណ៌ឡើង ដើម្បីជាហិតប្រយោជន៍ចំពោះអ្នកអាន អ្នកសិក្សាទូទៅ ។

ពិតមែនហើយ អត្ថបទនេះ អ្នកនិពន្ធអធិប្បាយតាមការពិតទាំងស្រុង គឺលោកឃើញយ៉ាងណា ឮយ៉ាងណា គិតយល់យ៉ាងណា លោក

កំសរសេរយ៉ាងនោះ, ប៉ុន្តែធម្មតាការពិតពេក រមែងប៉ះពាររទៅលើនេះលើនោះ នាំឲ្យកើតរង្កៀសខ្លះ កំមិនខានដែរ ។ តែណ្ហើយចុះ យើងសុំចម្លងទាំងស្រុងតាមអត្ថបទដើម ឥតហ៊ានកែ ហ៊ានបំផ្លើស មួយម៉ាត់ណាឡើយ ត្បិតចង់រក្សាលក្ខណៈដើមឲ្យនៅបរិសុទ្ធ, ហេតុការណ៍ចាស់ ៗ កំឲ្យនៅគ្រប់ សម្រាប់ឲ្យអ្នកអាន អ្នកសិក្សាឆ្លុះមើលឃើញរបៀបរបបការរស់នៅនៃស្រុកយើង និងចិត្តគំនិតរបស់អ្នកស្រុកយើងកាលពីសម័យនោះ ៗ ដូច្នេះ បើលោក-អ្នកអានឆ្ងល់ត្រង់ណា, ឃើញពុំសមត្រង់ណា កំសុំរិះគិត យកកាលទេសៈធ្វើជាប្រមាណ ទើបកាត់សេចក្ដីសង្ស័យទាំងនោះបាន ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងសេចក្ដីកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តលោកកវី សុត្តន្តប្រីជា **ឥន្ទ** ដែលបានទុកស្នាដៃជាច្រើនក្នុងអក្សរសាស្ត្រ និងវប្បធម៌ជាតិ រាប់ថាជាអ្នកប្រាជ្ញអក្សរសាស្ត្រមួយរូបយ៉ាងឆ្នើម ក្នុងដើមសតវត្សទី ២០ ។

ភ្នំពេញ ថ្ងៃទី ៣០ មីនា ១៩៦៧

ពុទ្ធសាសនបណ្ឌិត្យ

ពាក្យកាព្យ

និរាសនគរវត្ត

និរាសនគរវត្ត

១ និរាសរតន៍វត្តនគរសែនរបិត្ត

កាលចេញចាកណាកបរសមរមិត្រ
កែវដីរ៉ាគូដ៏វិតកិសម័យ ៗ
　　ដោយមានការបក្រពាក្យវក្យក្រស័ត្រ
ស៊ីសុវត្ថិព្រះកែវហ្វាសុឡាឲ្យ
ព្រះចៅក្រុង កម្ពុជាធិបតែ
មានព្រះទ័យហ្វាយប៉ងពោធិញ្ញាណ ៗ
ទ្រង់យាងមកនគរវត្តសមោសរ
បាត់បង់សន្ធរណ៍ទីបុកណ
បរិច្ចាគកដទ្រព្យប្រដាប់ទាន
បំពេញញាណសម្ពោធិបញ្ញា ៗ
　　កំណត់ថ្ងៃយាងនោះចុះខាងទៀត
ប្រាំបួនកើតភទ្របទមាសា
ថ្ងៃព្រហស្បតិលេខប្រាំឆ្នាំរកា
ពេលសុរិយោជ្រសែងព្រះរង្សី ៗ

លោកចៅហ្វាយខែត្រស្រុកព្រះដំបង
ជានាយកងបាត់ការពដការថ្មី
ព្រមទាំងលោកកុម្មិសែរអធិបតី
ចិត្តភក្តីត្រេកត្រង់ទាំងទ្វេហារ ៗ
រៀបចាត់ចែងតែងតួតាមទំនួល
ទៅទទួលព្រះបមចៅច័ក្រា
លោកក៏យកខ្ញុំបាទទៅផងណា
ព្រោះមេត្តាចង់ឲ្យយល់ទីបុពណ ៗ
គ្រាន់នឹងទ័តទទឹងប្រសាសន៍លោក
ក្រែងជួនស្ដោកកើតទោសមោះដល់ប្រាណ
ខំតែកាត់ចិត្តលះលាកល្យាណ
គូបុពណកាលកម្មចាំចាកបរ ៗ
ដល់ពេលផ្ដុំលោកធំចុះចាកស្ថាន
ឡើងរថយានទឹមសេះដ៏បវរ
សារថីជំនាញទាញបើកបរ
បត់បរចុះដល់កំពង់ទឹក ៗ

ពួកកាដការបារាំងទាំងខ្មែរយួន
សឹងតែងខ្លួនជូនដំណើរអឹកធឹក
ពួកទាហានជើងខ្មៅប្រចាំសឹក
ដង្ហែគ្រឹកបុះកប៉ាល់ជាស្រងា ៗ
នាយតៃកុងទាញខ្សែសប្លេកង
លាន់បីដងម័តឡូស្រាយយុថ្កា
សទិមពេញក៏ចេញចមឧត្ដរា
តាមគង្គាហូរត្រង់តម្រង់ចរ ៗ
តែកុងយួនចេះក្បួនបង្កូតត្រង់
កាត់ដម្រង់តាមជ្រោយប្រាំងសាគរ
បក្រក៏វិលកាយទឹកពន្លឹកខ្ពុរ
អ្នកនគររត់មើលគ្រប់លំនៅ ៗ
    កប៉ាល់លឿនដល់គយខ្ញុំគយគន់
យល់ដំបន់មេគយប្រចាំផ្លូវ
មានសសរគោមតាំងមុខលំនៅ
មើលៗ ទៅទីលំនៅមិនសមសក្ដិ ៗ
ផ្ទះយោកតាគយោលស្បៃរយោង

ភាពជាខ្មែរកែជាពេងយោងជាថ្នាក់
ឱគយនេះយ៉ាងជាគ្នាខាត់ប្រាក់
គ្រាន់តែត្រួតមើលអ្នកចូលចេញក្រៅ ។
នឹងមានហូតពន្ធដារការក៏ទេ
គ្រាន់តែគេចូលប្រាប់ក៏ហួសទៅ
ឱគយនេះអត់ពន់ជន់តាំងនៅ
ធ្វើតែស្រូវដាំច្បារចំការស៊ី ។
រាជការសៀមតាំងគយនៅចុងស្រុក
ពុំឃើញមានទំនុកឲ្យហូតអ្វី
កោតមេគយនៅចាំជាប្រក្រតី
រាជការថ្មីលោកលើកពុំបំរុង ។
ឱអ្នកគយគេធ្វើចំការស្រែ
មិនជួញប្រែយ៉ាងយើងអ្នកស្រុកក្នុង
កោតគេរកធនធានគ្មានកោងកុង
ស៊ូកក់ផុងជិតកាយក៏ត់តថា ។
ស្តាយតែរូបនារីពងស្រស់ឡៀ
បុះស្ងួនស្រូវត្រូវកំដៅព្រះសុរិយា

ដិតទាំងដីកក់ផងហ្នងកក្ដ្រា
អនិច្ចាជាតិអ្នកក្រត្រដរទៅ ៗ
ប្រសិនមានមាសប្រាក់និងសក្តិយស
ស៊ីក៏ខ្ពស់ដេកក៏ខ្ពស់ឥតមោះម៉ៅ
បំរុងលាបទឹកអប់និងប្រេងម្សៅ
កាល់ចាប់ខ្មៅតែងខ្លួនឲ្យនួនល្អង ៗ
តែងប្រកួតអួតឆោមប្រលោមប្រុស
ត្រកូលខ្ពស់យល់ហើយមិនកន្លង
នេះមកត្រូវកំដៅកក់ផង់ផង
ទឹងស្នាលស្នងបងចិត្តស្និទ្ធម្ដេចបាន ៗ
គន់ ៗ គិតអាណិតនារីតូច
កើតក្នុងពូជហីនយសខុសសន្តាន
តោងត្រដរនឿយយ៉ាកលំបាកប្រាណ
ទម្រាំបានមាសប្រាក់ធ្លាក់ដល់ចាស់ ៗ
ចាស់ហើយតើនឹងតែងតួម្ដេចល្អ
ប្រុសនឹងតថ្លៃទិញយល់ក្រណាស់
ឃើញជាចុះថ្លៃថោកល្មមបោកប្រាស

ការសង្វាសទឹងសង្វាតជាប់សង្វែង ៗ
សំណាងទន់ក្រជនតោងជន់អត់
ក្តីនឿយហត់គេស៊ីតាមដំណែង
គេអ្នកមានគេតែងកាយចិញ្ចែង
មិនដូចខ្លួននួនឯងកក់ស្រមក ៗ
អង្គុយគន់នារីឲ្យកិសរង់
កប៉ាល់លឿនដល់ចុងអន្លង់សក
ស្ទឹងក៏តូចបត់ក៏ខ្វ៉បីបួនប្រក
សំណាត់កកដេរដាសពាសពេញស្ទឹង ៗ
នាយតែកុងកាប់ប័ក្រពុះសំណាត់
ប័ក្រក៏កាត់ខ័តណែនកប៉ាល់ទឹង
ពួកម័តឡូចាក់ថ្នោលដោលទទឹង
ប័ក្រក៏រេផាត់វិលកប៉ាល់ក ៗ
ពួកអ្នកថ្នោលរឹងដោលសំណាត់ញែក
កប៉ាល់ជ្រែកវែកប្រានបានមួយគ្រា
សំណាត់ពុកកប៉ាល់ជាប់ចក្រខំពារ
មើលទៅនាប័ក្ររើសំណាត់រឹត ៗ

ខ្ញុំគន់មើលសំណាត់រ៉ាត់កប៉ាល់
ដូចរាគកាល់រូបកាយបុះបរិត
ពុំឲ្យរូបរៀបពីទីល្អិត(១)
បំបាំងបិទត្រៃលក្ខណ៍ហាត់ស្មើ ។
កាមរាគពេលតែសុត្តក្នុងលោក
ឲ្យសត្វនៅសៅសោកក្នុងលោកិយ៍
រាងកប៉ាល់ដូចរូបយើងប្រុសស្រី
ប្រាជ្ញាខ្ញុំមិនយល់កលត្រៃលក្ខណ៍ ។
ស្លាបច័ក្រគឺបញ្ញាផ្ការកកាប់កាត់
កងសំណាត់គឺរាតឲ្យលាកភ្លាក់
បានរូបចេញហាកទុក្ខសោករោគរាក់
អាស្រ័យច័ក្រគឺបញ្ញាក្ដៀវក្លាហាន ។
គ្រឿងកប៉ាល់ដូចកលអាការយើង
ដីទឹកភ្លើងខ្យល់គឺធាតុបួនស្ថាន
បន្ទតគឺសតិរំឭកបាន
ថ្នោលថោលប្រានគឺសមាធិចិត្តជាក់ ។

---

១ — តាមត្រូវ គឺ ល្អិត តែទីនេះ តម្រូវតាមពាក្យជួន ។

សំណាត់គឺបាបធម៌និវរណៈ
បិទបាំងកៈមិនឲ្យយល់ត្រៃលក្ខណ៍
ទឹកហូរវល់ដូចកល់សង្សារចក្រ
ឲ្យសត្វធ្លាក់នៅក្នុងអន្ទង់កាម ៗ
ទុអនិច្ចារូបកាយមិនណាយលាក
អំពីពកគនៅតែរឹងក្រឡឹងតាម
បានជាដល់ទុក្ខមកយំរហាម
ព្រោះមិនតាមពុទ្ធកិច្ចភ្លេចស្មារតី ៗ
ខ្ញុំគិត ៗ គួរសង្វេគរូបអាត្មា
មកលុះចុះតណ្ហាការលោកិយ៍
ឃើញធម៌ហើយក៏នៅតែនឹកស្រី
ជាចំណីពកគ៏រឹតបិទមុខមាត់ ៗ
កាច់មិនបានព្រានមិនបែររឹងតែបិទ
អនាថចិត្តអាណិតចៅមកប្រោសព្រាត់
គ្រាន់ទឹងតាមព្រះបន្ទូលជាបន្ទាត់
លោកិយ៍អត់កត់មិនទឹងទទឹងគាង ៗ
យកធម៌ព្រះមកលះភ្លើងមិនឈប់

ងងឹតឈឹងដូចយប់មិនយល់កង
ឱលោកិយ៍លះក្រគ្រាន់តែព្រាង
ដូចគេលាងព្រៃខ្មៅត្រូវជ័រទឹក ៗ
ខំដុសលាងយ៉ាងណាមិនឡើងពណ៌
ជាតិជាជ័រជាប់នៅខ្មៅស្រមឹក
ដូចកិលេសជាប់សត្វបាត់ជាសឹក
អ្នកកុំនឹកគិតលាងឲ្យជ្រះបាន ៗ
ដូចរូបខ្ញុំខំលះរឹតតែរឹង
ទប់មិននឹងតាំងមិននៅផ្លូវកម្មដ្ឋាន
អង្គុយគិតយកធម៌ទូន្មានប្រាណ
ដូចគេច្រានសំណាត់សាត់មួយគ្រា ៗ
ដល់ហួសទៅសំណាត់សាត់មកវិញ
ប្រមូលពេញដូចដើមណានួនណា
ឱសំណាត់នេះប្រៀបដូចតួតណ្ហា
ទឹងកាប់ឆ្ការយ៉ាងណាក៏ណែនវិញ ៗ
គន់សំណាត់សាត់ជាប់ចុងចំការ
ទាំងខ្មោចឆ្កែខ្មោចឆ្មាត្រាពាសពេញ

ខ្ទះរលួយខ្ទះប្រែះពោះវៀនចេញ
ក្អែកត្មាតដេញគ្នាស៊ីជាកក្យា ៗ
ខ្ញុំគន់មើលសាកសពចំណីក្អែក
គិតសង្វែកដល់រូបនៃអាត្មា
ឱសត្វក្អែកមកលុះក្ដីមរណា
សូន្យដីព៉ាគេចោលបណ្ដែតទឹក ៗ
កាលពីរស់កឹងកាចអំណាចមាន
សត្វតិរច្ឆានជួបគ្នាមិនហ៊ានចឹក
ដល់ខ្លួនស្លាប់គេអូសបណ្ដែតទឹក
ក្អែកត្មាតត្រឹកបឹកស៊ីមិនគ្រាន់ឡើយ ៗ
ឱអនិច្ចាសង្ខារសត្វទាំងឡាយ
តែបែកកាយរំលាយខន្ធទៅហើយ
គេក៏កើតខ្ពើមឆ្អើមពុំជិតឡើយ
យើងគេអើយគួរគិតផ្ចូរអនិច្ចា ៗ
ខ្ញុំបាទខំសង្វេគសាកអសុភ
ពគមិនឈប់ចេះតែពេលទាំងរូបា
នឹកតែទៅដល់ពៅកែវសុតា

អនិច្ចាថាតែមាត់ចិត្តមិនចំ ។
អសុភដប់សម្រាប់លោកលាងលាក
កំចាត់រាគចរិតចិត្តបឋម
ព្រះយោគីលោកសមាធិចុះអារម្មណ៍
បែកតែខំពុំចំអារម្មណ៍ឡើយ ។
យកសពឆ្កែមកប្រែនឹងរូបកាយ
មិនសោយណាយសោះណាលោកអើយ
ធ្វើម្ដេចហ្ន៎បានលោកឯណាអើយ
ជាកោះត្រើយណែផ្លូវឲ្យទានព៉ ។
មួយសង្ស័យនឹងពាក្យ "អន្សងសក"
ពាក្យប្រែបកដូច្នេះគួរសង្កា
សត្វអន្សង ពសកពីកាលណា
បានជាមកសញ្ញាឈ្មោះយ៉ាងនេះ ។
សត្វអន្សងមិនដែលសកសោះទេ
នេះហេតុអ្វីក៏គេហៅដូច្នេះ
ឬគេឃើញសំណាកនៅនេះអេះ
បានជារិះត្រិះនាមមកឥឡូវ ។

ងពិនិត្យមិនយល់សែនឆ្ងល់ពេក
ៗឈ្មោះញែកនាមសត្វពាត់មិនត្រូវ
ឱ្យង៏សក លោកណាឲ្យនាមហៅ
បានជានៅនាមជាប់ឥឡូវនេះ ៗ
តែបើគិតគួរកោតលោកបុរាណ
បេះគិតអានសន្ធតនាមយ៉ាងនេះ
ទីព្រៃសោះបេះឲ្យឈ្មោះហ្មោះហ្មះ
ពេញជាបេះកំណត់កត់នាមនៅ ៗ
អង្គុយគិតចិត្តក្វើនរំកើយខ្យល់
កប៉ាល់គ្រឿនលឿនដល់ព្រែកក្របៅ
ទឹកក៏នឹងពុំហូរបុះទៀតទៅ
ឃើញទឹកខ្មៅថ្លាយង់ឥតពកា ៗ
ក៏ដឹងថាជាទឹកទន្លេដល់
ទឹកស្ទឹងកល់ហូរទល់ប្រសព្វគ្នា
បានជានឹងពុំហូរត្រឹមនោះណា
នឹកសង្កា ព្រែកក្របៅ ហៅសែនឆ្ងល់ ៗ
ព្រែកនេះតើបែកមកពីណាអេះ

ឃើញតែបុងត្រឹមនេះមិនឃើញគល់
ឬព្រែកនេះទំនាបជាភាពទាល់
គួរពិភាល់ចិត្តណាស់ព្រែកក្នុងព្រៃ ។
ព្រែកនេះតើគេជីកឬកើតឯង
លោកមកតែងនាមក្រពៅនៅច្នេះនៃ
ខ្ញុំពីគ្រោះមិនអស់ក្តីសង្ស័យ
កប៉ាល់លឿនដល់កន្ត្រៃថ្ងៃក៏ទាប ។
ព្រែកកន្ត្រៃកាត់ត្រង់ត្រូវកញ្ឈាះ
ទីស្រឡះគេដើរបានរៀងរាប
ព្រៃដុះល្បោះ(១) ចុះតាមទីទំនាប
អ្នកស្វែងលាភរកត្រីអាស្រ័យបាន ។
ព្រែកកញ្ឈាះទីស្រឡះគេដើរដល់
ស្រុកមង្គលបូរីជាជ័យឋាន
គិតៗទៅ គួរកោតលោកបុរាណ
បេះគិតអានចាត់ព្រែកឈ្មោះថ្វែកគ្នា ។
មួយសង្ស័យទឹងនាមកន្ត្រៃនេះ

១— តាមត្រូវ គឺ របោះ ។

នរណារិះចាត់ឈ្មោះទុកច្នេះណា
វិស័យទីជាស្ថានព្រៃព្រឹក្សា
មកសញ្ញាហៅកន្ត្រៃសឆ្ស័យស៊ុន ៗ
ឬកន្ត្រៃលោកណាធ្លាក់នៅនេះ
បានជារិះយកនាមនេះមកគុណ
ឬមានជាងកន្ត្រៃគេនៅមុន
ឬអ្នកបុណ្យឲ្យឈ្មោះព្រោះជាប់គ្នា ៗ
រំពឹងគិតមិនយល់ដល់ព្រលប់
ពេលក៏យប់ម៉ោងមួយដល់បាក់ព្រា
តែកុងពាញសប្លេឡើងបីសា
ប្រាប់នាវាឲ្យចៀសកប៉ាល់ចូល ៗ
លុះចូលដល់ស្ពានផែមុខសាលា
បោះយុថ្កាចតចងតាមទំនួល
លោកមោនសៀ(១)នាយគយចិត្តស្រោះស្រួល
មកទទួលលោកធំ(២) ទៅគ្រឹហា ៗ

---

(១) – មកពីភាសាបារាំង Monsieur ។

(២) – លោកធំ ជាពាក្យជំនាន់នោះ ហៅចំពោះ Résident បារាំង ដែលនៅត្រួតការប្រចាំទីរួមខេត្តនីមួយៗ ។

ចៅភ្នាក់ងារនាំឧសផ្ទុកកប៉ាល់
ដាក់ពេញទាល់ទាំងល្វែងនៃនាវ
លោកចុល័ដ្ឋហាត់រៀនមួយវេលា
ទាំងអស់គ្នាគេសែនសប្បាយចិត្ត ។
តែខ្ញុំមួយព្រួយប្រាណរំខានសល់
ចង់តែដល់បានយល់ចមបពិត្រ
អស់កជការទឹងបានវិលស្ថានស្ថិត
មិនដឹងគិតកែដូវឲ្យត្រូវឡើយ ។
អង្គុយគិតដើរគិតដូចពុលផ្សែត
ពគក៏តែពេលពលកមិនស្បើយ
លុះដល់ម៉ោងពីរខ្យល់រំភើយ
គ្រាន់លំហើយក្តីទុក្ខពីមុខបាន ។
មើលទៅស្ទឹងបាក់ព្រោជាផ្លាធំ
ពួកអ្នកឈ្មួញមកជុំទាំងបីដាន
មួយគឺស្ទឹងមង្គលបូរីហាន
ពីរគឺដានព្រះដំបង បីទន្លេ ។

ទីស្ទឹងនោះកាលពង្សសៀមតាយចែក
ចាត់ឲ្យហៅសាមយ៉ែកភាសាគេ
ព្រោះដានបីចេញទៅមាត់ទន្លេ
បើតាមគេឃើញត្រូវជាផ្លូវបី ។
ឯពាក្យហៅថ្នាក់ព្រាពីបុរាណ
គ្មានភិយ៉ាន(១)ឡាក់ហាននឹងរូបអ្វី
ឬបាក់ព្រា បាក់នេះជាពាក្យថ្មី
បុរាណស្តីថា បាត់កាំបិតព្រា? ។
នរណាបាត់កាំបិតនៅនេះអេះ
បានជាជាប់នាមនេះដូច្នេះណា
ស័ព្ទកាំបិតយល់លើសយារវាចា
មកសញ្ញាថាតែបាក់ព្រាវិញ ។
ឥបានលោកប្រាជ្ញណានឹងសួរសាក
ឲ្យដឹងពាក្យបាក់ព្រានេះឯងមិញ
រំពឹងទៅមិនយល់សល់សែនម្ញិញ

១– ភិយ៉ាន (សៀម) = គិតតាគ ។

កាលណាលោកនឹងចេញកប៉ាល់ទៅ ៗ
រំខានទុក្ខនឹងមូសវាយាយី
ឯណាទុក្ខនឹងស៊ីម៉ៃមីខៅ(១)
ឯណាទុក្ខនឹងទឹកដល់ឆោមឆ្ងៅ
ឯណាទុក្ខនឹងក្ដៅចង្អៀតគ្នា ៗ
ទឹកទន្ទឹងបានតិចលេចឡុងបុត
លាបសសុទ្ធអុំអែបមកម្នីម្នា
លោកកុម្មីសែរក៏ឡើងកាន់នាវា
រឹងឲ្យស្រាវយុថ្កាចេញវៃ ៗ ៗ
ខ្ញុំគ្រាន់ស្បើយក្ដីមោះព្រោះចង់ឆាប់
ច័ក្ររឹងកាប់ទឹកខ្ចាតខ្ចរទាំងព្រៃ
កប៉ាល់គ្រឿនព្រឿនលើជលាល័យ
បើកអស់ដៃមើលព្រៃប្រប៉ះគ្នា ៗ
ដល់ត្រែកពកាច់ប្រែបែរឧត្ដរ
ក៏វែងបរតាមបថទីគង្គា
ទឹកសន្ស័យត្រែកពនេះមហិមា

១— ម៉ៃមីខៅ (ពាក្យសៀម) = គ្មានបាយ ។

តាំងនាមាឃើញកើនលើសប្រមាណ ។
ពាក្យត្រែកពប្រាជ្ញនាមព្រះពុទ្ធ
មិនគួរគេមុកចុតឈ្មោះភូមិឋាន
ទីនេះសោតពួកនេសាទគេរាប់អាន
តាំងជាស្ថានឋាយាប(១)ចាប់ត្រីទេ ។
នេះហេតុអីយកនាមព្រះឲ្យឈ្មោះ
មិនគួរសោះទឹងពាក្យអ្នកទទ្វេ
នរណាអេះចាត់នាមនេះមុនគេ
ឬគេគ្នេរព្រោះព្រែកបែកបីក្ងោះ ។
សព្វត្រែកពប្រែថាកពទាំងបី
ព្រះជិនស្រីជាត្រែកពចំពោះ
ព្រោះព្រះអង្គវិសេសគុណពីរេះ
បានជាឈ្មោះព្រះចមត្រែកពការ ។
ឯព្រែកនេះពុំឃើញវិសេសអ្វី
វិសេសតែទឹងត្រីជាអាហារ
ពុំគួរតាំងនាមស្មើសាស្តាចារ្យ
ឬហៅដោយវោហារអស្ចារ្យក្រៃ ។

១— ឋាយាប = អារក្សទឹកសម្រាប់អ្នកនេសាទគោរព ។

រំពឹងគិតមិនយល់សព្ទត្រែកព
ចង់តែឈប់ទៅមើលទីនោះនែ
ជាមានអ្វីសាក្យីកណ្ដាលព្រៃ
គួរសង្ស័យទឹងពាក្យត្រែកពនេះ ។
ឬសព្ទត្រែហៅក្រែលោកតាំងឈ្មោះ
គង់ពីគ្រោះតាមហេតុមានប្អោះប្អេះ
ឬពីដើមព្រះយាងមកនៅនេះ
បានជារិះតាំងហៅត្រែកពហោង ។
ចុះលោកណាដឹងការហេតុដើមដាន
សូមមេត្តាប្រោសប្រាណប្រាប់ខ្ញុំផង
ខ្ញុំពីគ្រោះមិនយល់រឿងហ្មួហ្មង
កប៉ាល់ឆ្លងកាត់យោគយាងយាវខ្ចី ។
លឿនលន្ទឹមតាមបត់យាងយាវត្រង់
កាត់តម្រង់បែរត្រង់ដល់ភូមិថ្មី
ភូមិនោះមានគេនៅជាប្រក្រតី
បត់ក៏ខ្ចីជាប់នាមពាបសីមា ។

ឱស្រុកពាមតាត់នាមឈ្មោះពិរោះ
គេបញ្ចុះសីមាពីកាលណា
ត្រើយខាងជើងមានព្រែកបែកជាស្នា
ឮគេថាស្ទឹងនោះទៅទឹកជោរ ។
ឱទឹកជោរទឹកហូរពីក្នំណា
ធ្លាក់មកពាមសីមាជាសពេញពោរ
ទឹកទន្លេឡើងកល់ទល់មិនហូរ
កាត់ទឹកជោរដល់ព្រាត់វត្តឈើខ្មៅ ។
គន់មើលទៅវត្តលោកលើគោកស្រួល
ជាទីទួលសមជាអាវាមនៅ
ឯវត្តនេះយកនាមឈើមកហៅ
នាមឈើខ្មៅលោកណាតាំងនាមនេះ ។
ឬវត្តនេះស្រីខ្មៅទៅធ្វើទេ
យកនាមគេមកតាំងទុកដូច្នេះ
ឬពីដើមមានឈើខ្មៅនៅនេះ
បានជាវិះតាំងនាមមកឥឡូវ ។

ពាក្យឈើខ្មៅហៅហាក់នាមខ្មៅបង
ចិត្តចាប់បងនឹកដល់កែវឆោមខ្មៅ
ឪព្រះគុណព្រះកែវវត្តឈើខ្មៅ
ខ្ញុំណាទៅនគរវត្តព្រាត់កនិដ្ឋា ។
សូមព្រះគុណប្រោសជួយចក្រពង្ស
ឲ្យស្តេចទ្រង់ចំរើនដោយយសា
ប្រោសប្រាណខ្ញុំឲ្យបានទីឧកញ៉ា
កបសក្តារឡីស៊ីសុវត្ថិ ។
មែនបើខ្ញុំសម្រេចដូចប្រាថ្នា
ខ្ញុំនឹងគិតហៃហាផ្កាមកថ្វាយថ្វាត់
សូមកុសលព្រះគុណជួយបំបាត់
សព្វទុក្ខភេទខាត់សកលកាយ ។
មួយសូមជ័យជំនះឈ្នះសត្រូវ
ទៅតាមផ្លូវកុំឲ្យមានអន្តរាយ
ទាំងពាលម្រឹគយង់ឃ្នងផងទាំងឡាយ
ចៀសឲ្យឆ្ងាយដោយអំណាចព្រះបរមត្រៃ ។
ខ្ញុំសំពះបន់ព្រះវត្តឈើខ្មៅ

កប៉ាល់គ្រឿនលឿនទៅតាមជលស័យ
ត្រូវព្រះពាយរំភើយខ្ញុំទឿយក្រៃ
ក៏លក់តាមសម័យយប់នោះឯង ៗ
លុះបើកដល់មាត់ពីរចេញទន្លេ
កប៉ាល់របើកពុះធ្លងវាលវែង
វាយោយោកផាត់មករលកផ្សែង
ខ្ញុំបាទឯងក៏ក្រោកចាកដំណេក ៗ
អង្គុយគន់មើលទឹកទន្លេសាប
ឡើងលិចដាបព្រៃព្រឹក្សពន្លឹកពេក
មើលទៅទិសទក្សិណសែនវែង
ឃើញតែមេឃម្លូជិតនឹងទឹកឈឹង ៗ
គន់ទៅទិសឧត្តរគ្លៀសាន
ឃើញជាដានព្រៃរង់វែងរវឹង
មើលទៅទិសបស្ចិមវាលដូចបឹង
ទឹកឡើងនឹងពោរពេញមើលល្វោះៗ ៗ
កប៉ាល់រឹងចក្រដើរស្ទើមិនឈប់
រលកខ្ទប់ស្មើរខ្ទាត់ចក្រពានពុះ

រលកយោលខ្ពោលឡើងដូចគេបោះ
កប៉ាល់ស្ទុះទឹកបែកញែកសាចដះ ។
ក៏យោបោកកប៉ាល់បែរលេលឿន
រលកគ្រឿនច័ក្រគ្រាន់បើកជំនះ
តែកុងកាប់តាមកៀនរលកដះ
កប៉ាល់រះទឹកពយបែកថ្កាត្រែង ។
មើលទៅទឹកធំពន្លឹកគួរតែខ្លាច
រលោមស្វាចលិចព្រៃមើលបែកផ្សែង
ទឹកសង្ស័យទន្លេសាបនេះឯង
លោកណាតែងនាមត្រូវទំនងម្ល៉េះ ។
ពាក្យហៅថាទន្លេខ្មេរមិនដល់
សព្វនេះយល់មិនត្រូវពាក្យអ្នកបេះ
បាលីទឹកគ្មានតួ “ទ” ទេអេះ
ហៅដលេដូច្នេះទើបបានត្រូវ ។
នេះមកហៅទន្លេអក្សរ “ទ”
យក “ទ” ជា “ដ” ប៉ុម្តេចគូរ

តួ “ន” ជាវគ្គន្តប្រកបនៅ
ស្ដាប់ៗទៅមិនត្រូវពាក្យបាលី ។
ឬបុរាណគេហៅ ជលេ ទេ
ដល់ក្រោយ យារពាក្យគេកើតពាក្យថ្មី
ទៅជាហៅទន្លេខុសបាលី
ឬសំដីបុរាណហៅយ៉ាងនេះ ។
ឬសព្ទនេះជាពាក្យសំស្ក្រឹត
លោកប្រសិទ្ធតួ “ដ” ជា “ទ” អេះ
ធ្វើម្ដេចហ្ន៎បានអ្នកប្រាជ្ញណាបេះ
នឹងសាកសួរសព្ទនេះឲ្យច្បាស់ព៉ ។
ទីទន្លេនេះធំមើលឃ្លាត់ត្រើយ
លោកណាអើយមកសាងយ៉ាងច្នេះណា
ឬក៏កើតពីបឋមកល្ប
ជាធម្មតាទឹកដីពីបុរាណ ។
នឹកៗ ទៅគួរកោតធម្មជាតិម៉្លេះ
បេះរិះឲ្យកើតជាភូមិស្ថាន
ជាទន្លេព្រែកស្ទឹងបឹងបួបាន

សម្រាប់ទុកជាស្ថានមច្ឆានៅ ។
ទីខាងលើបេះធ្វើជាទួលគោក
សម្រាប់លោកអាស្រ័យនៅឥតសៅ
តាំងជាភ្នំក្រំថ្មតទៀតទៅ
ជាលំនៅសព្វសត្វម្រឹគបក្សី ។
ឱជម្ពូជាតិបេះបាត់ជាជាន ៗ
សម្រាប់ទុកជាស្ថានយើងលោកិយ៍
លោកណាអេះបង្កើតអស់ទឹកដី
តាមបាលីថាកើតដោយធម្មតា ។
តែខាងសាសន៍អារ៉ាបទូវជ្វាចាម
គេស្ដីតាមតម្រាវ៉ៅហារថា
ទឹកដីនេះគឺអង្គព្រះអាឡា
យៈហោវ៉ាគេសាងសម្រាប់លោក ។
ខ្ញុំពិគ្រោះមើលតាមគម្ពីរជ្វា
ឃើញខុសគ្នាទីងហេតុទឹកដីគោក
បើអាឡាសាងមែនគួរអេជៀគ
ឲ្យត្រូវគ្នាទាំងលោកនោះយល់មែន ។

នេះទឹកដីនឹងសព្វសត្វមនុស្សម្នា
ឃើញពុំធខុសគ្នាទៅតាំងផែន
ឯណាល្អក៏ល្អលើសតាំងដែន
ឯណាសោសោសែន(១)តាំងភាព ។
ដូចដីយើងបាត់ដំបងជាតិដីខ្មៅ
ធ្វើស្រែស្រូវកើតផលតែពល់គ្នា
ស្រុកសៀមរាបម្តេចដីខ្សាច់មហិមា
ធ្វើចំការស្រែស្រូវមិនសូវផល ។
មួយគឺខាងអឺរុបម្តេចចាត់ល្អ
មនុស្សក៏ចម្រើនធំតាំងសាកល
ខាងឥណ្ឌាមនុស្សខ្មៅ ៗ ពិកល
ខាងមណ្ឌលយើងម្តេចមនុស្សតូចទាប ។
មួយព្រឹក្សាលតានាមដូចគ្នា
សេទុជាម្តេចខុសគ្នារៀងភាប

១— សោ ភាសាអ្នកស្រុកបាត់ដំបង-សៀមរាប បានន័យថា : អាក្រក់, គឿយហត់, គំរក់ ៗ សោសែន = អាក្រក់ពេក ៗ

ទាំងសត្វសោតក៏ខុសអត្តភាព
ខ្លះក៏ទាបខ្លះក៏ខ្ពស់ឃើញខុសគ្នា ។
បើអាឡោ សាងមែនម្ដេចដូច្នោះ
ខ្ញុំពីព្រោះមិនសមនឹងផ្ងាថា
វិស័យព្រះនោះប្រៀបដូចបិតា
តោងមេត្តាដល់បុត្រស្មើព្រះទ័យ ។
ទេះមកសាងឲ្យកូនមិនស្មើមុខ
ជាអាពុកមនុស្សឬខុសនិស្ស័យ
ស្ដាប់ទៅយល់មិនត្រូវអធ្យាស្រ័យ
ទឹកដីព្រៃក៏កើតដោយធម្មតា ។
ដូចយ៉ាងទឹកទន្លេនិងសមុទ្រ
ឃើញធំផុតទូលាយឆ្ងាយណាសា
ពួកអ្នកឈ្មួញដើរជួញរកកោក្តា
សឹងសែនមហាលំបាកដោយព្យុះខ្យល់ ។
ឬអាឡោឥតប្ងាពួកអ្នកឈ្មួញ
មិនឲ្យគ្នាដើរជួញក្រោមណ្ឌាល
បានជាមកបង្កើតជាព្យុះខ្យល់

ឲ្យលិចលង់ទូកទ័លទាល់វេទនា ៗ
អើបើយ៉ាងខ្មែរយើងមិនចូលសាសន៍
គួរធ្វើផ្លាស់ទៅចុះក៏ឥតថា
ចុះពួកផ្កាដែលគ្នាខំឧស្សាហ៍
ប្រតិបត្តិសព្វគ្រាតាមមហាម៉ាត់ ៗ
ឯណាយប់គ្នាបួសកាន់ខន្តី
ថ្ងៃឡើងធ្វៀតបង់ត្រីសំឡេះសត្វ
ឯណាគ្នាហ៊ានឲ្យតុកតួនកាត់
ខំប្រតិបត្តិមហាម៉ាត់មិនឲ្យឆ្គង ៗ
គួរឬអាល័សះឡើមិនប្រោសប្រោណ
មកក្លែងធ្វើផលបានធំកន្ទង
គ្នានាំព្រៃទៅលក់ស្រុកបាត់ដំបង
ឲ្យគ្នាហ្មងធ្វងទៅត្រូវព្យុះខ្យល់ ៗ
បើយើងជាអាល័សះឡើមិនធ្វើប្នេះ
ទីត្រង់ណោះគួរធ្វើឲ្យកើតថ្នល់
ឲ្យអ្នកទូកដើរស្រួលមិនតោងរវល់

នឹងព្យុះខ្យល់ដូចយ៉ាងអាឡាសាង ។
ទីត្រង់នោះគួរសាងជាកោះធំ
ឲ្យកិរម្យមនុស្សនៅទាំងសងខាង
តាំងក្បាលកោះឲ្យកើតជាព្រះប្រាង្គណ៍
មានមាត់បាងចូលចេញឲ្យសប្បាយ ។
នេះអាឡាមកសាងទន្លេសាប
ជាលតែទឹកទៅរាបទូលាយឆ្ងាយ
មនុស្សទៅមកសែនយ៉ាកលំបាកកាយ
ព្រោះអន្តរាយដោយខ្យល់តែពល់គ្នា ។
អើពួកផ្កាគេថាព្រះគេសាង
នឹងអែបអាងមិនសមនឹងកិរិយា
ពាក្យនេះអញ្ជើញពិចារណា
ជាយកខាងធម្មតាឬអស់លោក ។
ឬយកខាងព្រះអាឡាដែលថានោះ
សូមពិគ្រោះមើលចុះតាមអធ្យាគ
ឯទឹកដីថ្ងៃខែសម្រាប់លោក

គួរប្រយោគមើលហេតុមើលកិរិយា ៗ
កំប៉ាល់ដើរលុះដល់ចុងក្អៀសថ្កាត់
តៃកុងចាត់ចូលចតបោះយុថ្កា
នាំគ្នាដេកសម្រាន្តតាមធម្មតា
អនិច្ចាតែខ្ញុំពុំលក់ឡើយ ៗ
ពុលរលកក្អកលើកទឹកដល់ផ្ទះ
កត់មិនឈ្នះគះមិនទឹងព្រលឹងអើយ
ត្រូវមកដេកកប៉ាល់ខ្យល់ក្ហើយ ៗ
ផាត់រំកើយរលកបោកធា ៗ ៗ
គន់ទៅខាងឃើញសើន(១)គោមពីរក្បោះ
ភ្លើងភ្លឺប្រុះប្រុង ៗ ក្នុងគង្គា
គោមពីរនោះឆេះនៅសព្វវេលា
តាំងជាផ្លាប្រាប់ផ្លូវស្រុកសៀមរាប ៗ
ខាងមាត់ពីរក៏តាំងគោមភ្លេងស្តាំ
អុជប្រចាំចូលចេញទន្លេសាប

១— ជិតគោម ឬប៉មខ្ពស់ សម្រាប់យាមល្បាត ។

ខ្ញុំគន់ៗនឹកកោតលោកដរាប
មកលះបាបលោកបុណ្យចេញធនធាន ៗ
ទិញប្រេងអុជគ្រប់ហ៊ានពាមទន្លេ
ទុកឲ្យគេអ្នកដើរក្នុងជលហ៊ាន
ដល់ពេលយប់នឹងដឹងទីដែនដាន
ចេញចូលបានឥតមានក្ដីបែងវែង ៗ
គោមនោះសោតចេះនៅជាប្រក្រតី
ដល់រាត្រីទើបឃើញភ្លើងភ្លឺទែង
ដល់ពេលថ្ងៃពុំយល់ព្រោះសូរ្យសែង
គេបាត់បែងថែមប្រេងដប់ថ្ងៃម្ដង ៗ
ខ្ញុំយល់ៗ សរសើរលោកបារាំង
លោកមកតាំងអុជគោមភ្លឺកន្លង
ប្រាថ្នាទុកជាទានឲ្យអ្នកផង
បានដើរឆ្លងឃើញភ្លើងជាសញ្ញា ៗ
ឯស្រុកខ្មែរតាំងតែពីនេះទៅ
មានតែសុខឥតសៅឥតទុក្ខា

បានបារាំងលោកតាំងគ្រងរក្សា
តែងសីមាកម្ពុជាឲ្យពណ្ណរាយ ៗ
តែត្រឹមទីទន្លេជាស្ថានស្ងាត់
មកចេះចាត់អុជភ្លើងប្រចាំហ្វាយ
រាស្ត្រទៅមករកតាមស្រុកឆ្ងាយ ៗ
ដើរសប្បាយមិនតោងវង្វេងផ្លូវ ៗ
ឯទន្លេតាំងតែពីបុរាណ
មិនដែលមាននរណាបំភ្លឺចៅ
ឥឡូវនេះមកបានបារាំងនៅ
ឲ្យអុជគោមទួទៅទាំងគង្គា ៗ
សែនរុងរឿងថ្កើងហើយទន្លេសាប
ពីនេះទៅដរាបឥតក័យា
ឯរាត្រីយប់នេះជួនវេលា
ខ្ញុំនិទ្រាពុំលក់ជាទុក្ខក្រៃ ៗ
បែរទៅទិលបូតិឃើញរស្មី
ព្រះរង្សីអរុណរះសែងថ្ងៃ

ពួកកប៉ាល់ក៏ភ្ញាក់ឡើងទីទៃ
ស្រាវយុថ្កាវ៉ៗ ថយម្នីម្នា ៗ
កប៉ាល់គ្រឿនលឿនចូលទៅតាមព្រែក
ណាចង្អៀតក៏ជ្រែកបែកជាផ្កា
តែកុងកាច់បត់តាមទីគង្គា
មើលព្រឹក្សាដុះហែតាមក្បែរផ្លូវ ៗ
ខ្លះដើមខ្ពស់លូតលាស់ខ្នែងលំពង់
ខ្លះទាបទឹកលិចចុងឃើញខ្មៅ ៗ
កោតហ្ន៎ឈើរនាមធន់ណាស់ទៅ
ទឹកលិចនៅប្រាំខែប្រែមិនក្ស័យ ៗ
ឱព្រៃអើយព្រៃដុះជារនាម
ខ្លះជាពមស្បាតជិតបិទសែងថ្ងៃ
ខ្លះខ្ពស់ស្រោងផុតទឹកពន្លឹកក្រៃ
សត្វអាស្រ័យជាស្ថានសម្រាន្តនៅ ៗ
កប៉ាល់បើកលុះដល់កន្លាយគម
ឃើញភ្នំក្រោមនៅខាងឯលិចផ្លូវ
ឱភ្នំក្រោមតូចល្មមមានមនុស្សនៅ

មើល ៗ ទៅពុំឃើញមានដើមឈើ ។
ជាភ្នំដិលត្រងិលមានតែស្មៅ
មានដើមពោធិមួយនៅកំពូលលើ
ក្រោយពោធិមានវិហារគេទើបធ្វើ
វត្តនោះតើលោកណាសទ្ធាសាង ។
ឯក្រោយផ្ចាវិហារមានប្រាសាទ
វិចិត្រស្អាតដោយថ្មកជាប្រាង្គ
ជារបស់បុរាណលោកសំអាង
ទំនង យ៉ាងបញ្ចុះព្រះធាតុក្យត្រ ។
ឬជាទីតម្កល់ព្រះបដិមា
សម្រាប់អ្នកសាសនាឡើងប្រណិបតន៍
ទ ប្រាង្គនេះលោកណាមកចែងចាត់
មាននៅស្ពានបង្ហាត់ខឿនខ្វាត់ខ្វែង ។
ឥឡូវនេះជំរុតទ្រុឌទ្រោមធ្លាយ
ថ្មរុះពាយតាមជាយជើងកំពែង
ស្តាយអើយស្តាយប្រាសាទប្រសើរស្តែង
បានលោកណាចាត់ចែងជួសជាថ្មី ។

មើលប្រាសាទលើភ្នំស្ទើរយំស្តាយ
មិនគួរមកអន្តរាយខ្ចាយដោយដី
ស្តាយតែស្នាដៃធ្វើស្មើកោសី
មិនគួរបីបែកបាក់ធ្លាក់ធ្លាយធ្លុះ ៗ
ខាងជើងភ្នំមានវត្តលោកសង្ឃនៅ
មានធ្លាផ្លូវឡើងទៅខាងវត្តនោះ
ឯភ្នំនេះស្តាប់ទៅយល់ពិរោះ
សញ្ញាឈ្មោះភ្នំក្រោមល្មមមានអាង ៗ
ព្រោះភ្នំគេសឹងតែនៅខាងលើ
មានដើមឈើដុះលើឃើញប្រូងប្រាង
ភ្នំមួយនេះមកតាំងនៅក្នុងបាង
មានទីអាងយ៉ាងនេះជាសាក្សី ៗ
បានជាហៅភ្នំក្រោមព្រោះក្រោមគេ
នៅខាងជាយទន្លេអ្នកធ្វើត្រី
ឥឡូវមានអ្នកស្រុកនៅប្រក្រតី
ដាំឫស្សីផ្លូងស្លាចំការចេក ៗ
ឯភ្នំនេះជាទីពីបុរាណ

សមជាស្ថានសំណាក់អ្នកវិវេក
នឹកសរសើរប្រាសាទប្រសើរពេក
ខ្ញុំក្រឡេកមើលទៅទីឧត្តក ៗ
ឃើញទីនាំងតាំងចតនៅរៀងរាយ
ប្រចាំទ្វីបមក្ករក្លាយក:សាយណា
ទូកតែហ៊ៅវ៉ៃតម្បូងភាពផាយម៉ា(១)
ក៏ដឹងថាព្រះទីនាំងព្រះចក្រី ៗ
ទៅភ្នាក់ងារត្រួតត្រាព្រះទីនាំង
ឲ្យចតតាំងតាមថែវចុងព្រែកថ្មី
ទូករាជវង្សចតក្នុងទូកកុងវៀយ
ក្រុមមន្ត្រីចតអមលោមក្រៅឆ្ងា ៗ
ទូកអស់នេះទ្រង់ឲ្យមកប្រចាំ
មុនទម្រាំព្រះបរមរាជា
ដល់ជប់កើតថ្ងៃសុក្រស្ដេចលីលា
យាត្រាដោយរាជនាវាកប៉ាល់ធំ ៗ

១— ភាពសេះផាយ គឺទូកទីតាំងអម្ពរ ។

លុះកប៉ាល់ពដការស្រុកព្រះដំបង
ទៅដល់ដងពលវែងជាចុងកុម(១)
លោកឲ្យបោះយុថ្កាចតប្រជុំ
អ្នកជំនុំនាំគ្នាមើលត្រៀបត្រា ៗ
លុះកប៉ាល់ចតស្រេចលេចទូកបី
ក្រុមមន្ត្រីសៀមពបទីឧកញ៉ា
មកទទួលលោកជំជាឥស្សរ
បីគេបកភាសាថែងការផង ៗ
លោកកុម្ម៉ីសែរអធ្យាស្រ័យតាមហេតុ
ចាត់ឲ្យលោកចៅហ្វាយខែត្រព្រះដំបង
នៅកប៉ាល់ឯក្រោយចាំព៉ប់រង
ទទួលអគ្គច្បាស់ច្បងស្ដេចយាត្រា ៗ
តែខ្លួនលោកនឹងលោកសង្ឃបីអង្គ
ពុំរង់ចុះទូកអ្នកឧកញ៉ា
ខ្ញុំបាទឯងជាបាវលោកមេត្តា
ឲ្យយាត្រាទៅមុនដោយកំសាន្ត ៗ

---

១ – តាមត្រូវគឺចុងភូមិ តែនេះតម្រូវតាមសម្ផស្សកាព្យ ។

ទើបដញ្ជូនហិបពូកដាក់ទូកស្រេច
មួយរំពេចក៏ចេញតាមជលស្ថាន
ពួកកំណែនកេណ្ឌចែវទំចែវប្រាន
កាត់ត្រង់ដានទីជ្រៅទឹកព្រែកជីកថ្មី ៗ
ចែវអែប៉បែអបខាងព្រះទីនាំង
ខ្ញុំក៏តាំងលួចគន់មើលស្រីៗ
ពួកអ្នកក្នុងតែងអង្គល្អប្រឹមប្រីយ៍
ចរីក្រ្ត័ហាក់ស្រីទេពកញ្ញា ៗ
សឹងប្រដាប់សង្វារចារុខ្សែដៃ
ទំហ៊ូផ្ទៃវិចិត្ររចនា
ទទឹមពេជ្រលេចសែងព្រះសុរិយា
សូរ្យកាន្តកែវកាញ្ចឆាប៉ព្រាតព្រាយ ៗ
ស្លៀកខៀនខាត់រ័តអេវខាំម៉ាស៊ុ(១)
ផាត់ចរីគន្ធរសពិដោរសាយ
ខ្លះតែងត្លួស្រុភាតភាតសៀមក្លាយ

១— ខាំម៉ាស៊ុ = ក្រម៉ាសី តាំកមាពណ៌ ។

ខ្លះតែងកាយអាវសាយក្លាយបារាំង ៗ
ពួកសាវឡើកន្ទូតទឹកប្រឡែងគ្នា
សើចហោហាហែហលខាងព្រះទីនាំង
ខ្លះមិនខ្លាចអំណាចពួកក្រុមរាំង
ក៏សើចខ្លាំងលើសគេរៃតែខ្លួន ៗ
ខ្លះអង្គុយសិយសក់កញ្ចក់ខាង
ខ្លះសំអាងសមសក្តិហាក់ទឹមនួន
តែងប្រកួតអួតអង្គទ្រង់ដោយខ្លួន
មើលសមសួនសមសក្តិព្រះចក្រា ៗ
ខ្ញុំគន់ ៗ សរសើរព្រះបារមី
ព្រះចក្រីជាត្បូងលើកេសា
កបនារីស្អាតៗ បាទបរិចា(១)
សែនមហាចំរើនព្រះកិត្តិយស ៗ
គន់ទៅទូកពួកសេវកាមាត្យ
សឹងស្អាត ៗ រុងរឿងដោយគ្រឿងខ្ពស់
តែងប្រកួតអួតគ្នាតាមសក្តិយស

១– ក្លាយពី បាទបរិចារិកា = ស្ត្រីអ្នកបម្រើជិតជើង។

បំរុងតាមកាមរសវេណីក្សត្រ ។
សរសើរទូកខុនណាងនូវនាងអ្នក
ខ្ញុំតែងដាក់និពសនេះខាត់ ៗ (១)
ពុំពិស្តារវិត្ថារឲ្យច្រើនអត្ថ
ព្រោះក្តីខាត់ពុំស្គាល់អ្នកភ្នំពេញ ។
បានជាតែងសង្ខេបបែបខ្លី ៗ
តាមសេចក្តីយល់ខ្លះមិនច្បាស់មិញ
បើខ្ញុំស្គាល់ឈ្មោះលោកអ្នកភ្នំពេញ
ទឹងតែងចេញឈ្មោះលោកឲ្យគ្រប់គ្នា ។
សូមទានទោសកុំខឹងខ្ញុំអ្នកតែង
មិនសម្តែងឈ្មោះលោកចូលផងណា
ត្បិតខ្ញុំអ្នកព្រះដំបងក្រៅសេមា
ហេតុដូច្នោះបានជាតែងកាត់ខ្លី ។
ពួកកំណែនបែរស្រូតតាមព្រែកជីក
សែនរិរែគមើលព្រែកគេជីកថ្មី
ទឹកក៏ពក់ហូរបាក់ធ្លាក់អាចម៍ដី

---

១. ខាត់ៗ = កាត់ៗ សង្ខេបៗ ។

ដែរទៅដល់ភូមិថ្មីឫស្សីស្រុក ។
ឃើញអ្នកស្រុកតែងផ្កាមាគ្គាល័យ
ដោតទង់ជ័យពាយរៀងតាមមាត់ព្រែក
ខ្លះតែគូប្រទូប៉ាប្រដាប់ផក(១)
បោះកំប៉ងតែងបកអុចសំអាង ។
គន់អ្នកស្រុកសៀមរាបសុភាពគួរ
នៅជាជួរដងស្ទឹងតាំងសងខាង
ស្ទឹងក៏តូចប្រាំងក៏ទាបជាភាពបាង
ទទឹងយ៉ាងបីព្យាមបាយប្រោកជ ។
រយៈផ្លូវទៅពីចុងក្បៀសឯង
ដល់កំពែងសៀមរាបលោកកំណត់
បានបីរយកោសិបប្រាំសិនគត់
លោកវាស់ទុកជាបទបែបលាយថែង ។
តែខ្ញុំចេញបាកទឹកន្ទាយគម
ថ្ងៃទៀបត្រង់ក៏ល្ហុមដល់កំពែង

---

១. ប្រទូប៉ា = ស៊ុមស្លឹកឈើស្រស់ ។ ប្រដាប់ផក = ប្រដាប់ទៅដោយផ្កា

ចែវចូលចតអែបស្ពានក្នាក់ផារតែង
ត្រង់កន្លែងសានខ្វែងត្រើយខាងលិច ៗ
ពួកបាវហោយកូនក្មួយជួយគ្នារើ
ទ្រព្យរបស់ដាក់លើគោករំពេច
ខ្លះក៏មានតែទៃនិងបង្វេច
ក៏ស្ពាយគេចឡើងគោកជ្រកគ្រឹហា ៗ
ហោយបាពំងតាំងរៀបគ្រឿងលើគោក
ចាំមើលលោកនៅទីខាងផ្លូវថ្លា
រង់រទេះកំណែនទឹងលីលា
ឡើងទៅនាប្រាសាទនគរវត្ត ៗ
លោកឧកញ៉ាស្មៀនត្រាសទ្ធាបុណ្យ
មកនិមន្តលោកសង្ឃទៅផ្ទះគាត់
ចាត់បង្ហាន់ប្រគេនតាមកិច្ចវត្ត
សម្រេចកត្តនៅផ្ទះលោកស្មៀនត្រា ៗ
ឯខ្ញុំបាទនាំកៀនទៅផ្សារត្រើ
ទិញចំណីអាស្រ័យតាមធម្មតា

ស្រេចកិច្ចនាំគ្នាចរយាត្រា
មកចាំលោកនៅនាមុខកំពែង ។
គន់មើលគ្រឹះស្ថានចៅហ្វាយស្រុក
សែនជាសុខសមសក្តិហាក់គួរស្ញែង
តាំងគ្រឹហា នៅនាក្រៅកំពែង
រៀបចាត់បែងតែងការទទួលស្ដេច ។
ដោតទង់ជ័យបីជាន់ជាជួរជុំ
ប្រកបគុំបុប្ផាផ្ការំលេច
កែមស្លឹកឈើផ្ញើស៊ុមប្រខូពេជ្រ
រៀបជាក្បាច់វល្លិ៍វណ្ណពន្ធពេនពាក់ ។
មានសៀរក័ស៊ីប៉ាល់បារាំងសែស
នាយប្រទេសចាត់ការទាហានសក្តិ
យកកំពែងសៀមរាបជាសំណាក់
តាំងពិភ័ក្តិរក្សាការសត្រូវ ។
ខ្ញុំគន់មើលកំពែងវែងរឹង
ស្កាត់គេពបឹងពុំមាននរណានៅ

ព្រៃដុះជិតស្បាតជិតទាំងក្នុងក្រៅ
សែនហ្មងសៅមើលទៅគួរតែស្តាយ ៗ
ប៉មជម្រុតទ្វារទ្រុឌធ្លាក់ទីទៃ
ពួរពោធិជ្រៃជ្រៀតចាក់បាក់ធ្លុះធ្លាយ
លោកបារាំងតាំងឲ្យរើទំលាយ
យកទៅវាយបំបាក់ចាក់ផ្លូវធ្លា ៗ
ទុកំពែងគេតែងដោយថ្មក្រៀម
ស្នាដៃសៀមគេធ្វើកាលយុទ្ធនា
ស្រុកខ្មែរយើងនឹងយួនកើតច្បាំងគ្នា
សៀមធានាព៉ប់រងសង្គ្រាមយួន ៗ
លោកចៅឃុនបឪនាយបង្គាប់
ជាមេទ័ពលើកចេញមកតាមក្បួន
ទើបឲ្យកកំពែងប៉មមាំមួន
ចាត់ជាក្បួនបន្ទាយការសត្រូវ ៗ
តាំងមកដល់ពព្យលោកអង្គរវៃយម
លោកសមសែមចាត់ចែងតែងតាំងទៅ

កាលណោះឯងកំពែងសុខឥតសៅ
ដល់ឥឡូវត្រូវដែពជការថ្មី ។
លោកឲ្យរើទៅវាយដាក់ផ្លូវថ្លា
សម្រាប់ឲ្យមនុស្សម្នាដើរប្រក្រតី
ខ្ញុំគិត ៗ អនិច្ចំទាំងបូរី
តែទឹកដីគង់ដល់ផ្លូវអនិច្ចា ។
ឲស្រុកសៀមរាបជាភាពចាស់
សឹងខ្សាប់ជាសមិនថាទីត្រង់ណា
អ្នកនឹងរកប្រយោជន៍ស្រែចំការ
នឹងបានផលប៉ុនណារក្សាកាយ ។
មួយសង្ស័យនឹងស្រុកសៀមរាបនេះ
បុពណារិះឲ្យឈ្មោះខុសបរិយាយ
ស្រុកខ្មែរទេម្ដេចគេយកសៀមលាយ
តាមបរិយាយសាវតារតម្រាមាន ។
កាលព្រះបមបក្រើត្រើនេត្រក្សត្រ
គ្រងសម្បត្តិឥន្ទប័តបូរីស្ថាន

គឺនគរធំនៅជាប្រធាន
ចមក្សត្រក្សាន្តមានបុណ្យលើសនានា ។
មានព្រះនេត្របីភ្នែកប្លែកជាងជន
នេត្រកណ្ដាលតែគន់មើលនរណា
អ្នកនោះឯងក៏ដល់ក្ស័យជីវ៉ា
ពួកកាពក៏ស្វែងក្រែងបារមី ។
លុះណាងស្នោគឺសៀមជាសួយទឹក
កជាសឹកលើកមកវាយបូរី
ដល់មកទីត្រង់នេះបោះយោធី
តាំងជាទីសមរភូមិជ័យ ។
គ្រាន់ប្រាបដល់ព្រះនរិន្ទ្រពិនក្រស័ត្រ
ចមឥន្ទប័តក៏ទ្រង់ព្រះក្រោធក្រៃ
ទើបលើកពួកចតុរង្គក្នុងវៀងជ័យ
ចេញតដៃតែរឹទ្ធីហាន ។
មកដល់ស្រេចស្ដេចបើកព្រះនេត្រកែវ
តែមួយថ្ងៃត្រូវសៀមស្ងៀមមិនបាន
បោលអាវុធចាកដៃលុតក្រាបក្រាន

កបពុំហ៊ានតឫទ្ធិតវិញទៅ ៗ
ហេតុដូច្នោះបានហៅថាសៀមកប
ព្រោះមានភាពសៀមខ្លាចព្រះចមហៅ
បុកណាពជចារឹកតាំងនាមនៅ
ដល់ឥឡូវសៀមប្រែហៅសៀមក៉ត ៗ
ពាក្យសៀមក៉តប្រែថាសៀមឥតក្រែង
តាំងសំដែងឥទ្ធិឫទ្ធិគិតប្រមាទ
ដើរទន្ទ្រានពានរុកសីហនាទ
មិនក្រែងជាតិកម្ពុជាវេលានោះ ៗ
ព្រោះស្រុកនេះជាស្រុកឡើងស:យ៉ាម
សៀមធ្វើតាមអំណាចឥតខ្លាចសោះ
ពាក្យ "ក៉ត" សព្វនេះប្រែដូច្នោះ
បើកផ្ល:វិញនោះជាដែនស្រុក ៗ
ទំនងយ៉ាងសៀមប្រើ "ផ្ល" ជាខ្យល់
ប្រយោគដល់តួ "ត" តាំងជាមុខ
ខ្ញុំពីគ្រោះសព្វក៉តឧបាតទុក
ឥឡូវស្រុកបានមកខ្មែរវិញហើយ ៗ

គឺបានដោយអំណាចភជនិវេសន៍
ក្រុងបារិសយើងតាំងជាកោះកើយ
សៀមបាងកកលូកមកមិនបានឡើយ
យើងបង្ហើយ សៀមក៉ត ហៅ សៀមរត់ ។
ព្រោះកាលសៀមប្រគល់ទឹកដីឲ្យ
ត្រឡប់ក្រោយវិលទៅបាងកកហ្មត់
ហេតុនោះគួរពួកយើងបោះប្រាកដ
សន្ធរះហៅស្រុក សៀមរត់ វិញ ។
ពណ៌នាសៀមពបគាបសៀមក៉ត
សែនអនាថនឹកឡើងគួរតែម្នេញ
ព្រោះពីដើមចុះយ្លួនជួនសៀមវិញ
ឥឡូវពេញដូចមុនគុណបារិស ។
អើស្រុកខ្មែរកែមុខបានសុខសាន្ត
ព្រោះរួមស្ពានក្នុំពេញភជនិវេសន៍
កិត្តិយសសុសសាយទូប្រទេស
បារាំងសែសវិសេសជាបិតា ។
មួយដូចយ៉ាងប្រាសាទនគរវត្ត

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ពុកណាក្សត្រចាត់សានក្នុងសេមា
យូរអង្វែងពុំចែងជាពង្សណា
ទៅជាព្រៃព្រឹក្សាស្ងាត់នៅ ។
ពុំមានលោកឯណាដួសដុលបាន
បោលជាស្ថានសមសាន្តសែនហ្មងសៅ
ដល់ឥឡូវបានលោកបារាំងទៅ
លោកចាត់ផ្លូវដួសដុលវិបុលា(១) ។

ពណ៌នាបន្តិចលេចរទេះ

ព្រមទាំងសេះជំនិះលោកឥស្សរ
បរមកដល់ចែលចូលម្នីម្នា
ខ្ញុំនាំគ្នាផ្ទុករបស់ហើយបរទៅ ។
លោកកុម្មីសែរជិះសេះបរទៅមុខ
ពួកអ្នកស្រុកនាំគ្នាមើលខ្មួលខ្មៅ
ពួកខ្ញុំបាទដើរឃុំរទេះទៅ
បរតាមផ្លូវខ្សែលួសលោកដួសថ្មី ។
ព្រះទិនករបរបែរអរុណរៃឆី

---

១ វិបុល = ក្រៃលែង, បរិបូរ ។

កំដៅសែងព្រះអាទិត្យរឹទ្ធិរង្សី
ពួកអ្នកដើរសែនក្ដៅសៅធរី
ញ័រឥន្ទ្រិយញើសសស្រាក់ប្រឡាក់កាយ ។
អនិច្ចាតែខ្ញុំគ្មានឆ័ត្របាំង
ត្រូវកំឡាំងព្រះអាទិត្យរឹតក្រហាយ
ឯណាទុក្ខនឹងនឹកដល់ឆោមឆាយ
សេចក្ដីហ្វាយថ្វាយមាសនិពសមក ៖
ស្ដាយអើយស្ដាយកាយកែវកនិដ្ឋា
មកផងក៏នឹងនាំមើលប្រកល្ហក
ឱដើមពោគដូចពោគពាគរឹតតេក
ទៅដើមធ្លកមិនធ្លាប់មកឯកា ។
គន់ព្រឹក្សាលតាផុះដោយព្រៃ
ខ្លះលូតលៃលំពន់ទ្រន់ផ្លែផ្កា
សកុណជាតិហើរចាប់ចុងសាខា
ចឹកផលាសត្វសា៊ទអនេកក្រៃ ។
ភមរីហើរត្រង់គន្ធ់ចរ
ត្រឹបកេសរបុប្ផាពនាល័យ

សត្វហ្វឹង ៗ ទ្រហឹងកណ្ដាលព្រៃ
ប្រឡំសត្វពេរៃបន្ទឺសៀង ។
សែនស្រណោះសត្វសោកវិវេកចិត្ត
ទំប្រជិតសារិកាជាគូគៀង
កោកិលោ(១)លោតលេងទំរវៀង
បក្ដោញសៀងក្ងាំងក្រាងក្រអៅ(២) ។
គន់ចំបក់ដូចបងចំបែងចិត្ត
ចៅដើមខ្វិតដូចបងមកខ្វែងចៅ
ឱដើមសោកដូចបងមកសោកសៅ
ដើមស្រឡៅនៅស្រឡាញ់បេញបោលមក ។
ឱដើមថ្កាន់គេផ្ដាប់លាបដំបៅ
ដើមស្រឡៅធ្វើបែវគួរកាប់យក
ផ្កអើយផ្កមិនធ្លាក់ផ្លែចុះមក
ខ្ញុំនឹងយកធ្វើប៉ុយបន្ហុយពោះ ។
គន់ដើមយាងពងយោរយោកដោយខ្យល់
គេកាប់ផុតយកដ័ធ្វើចន្ទុះ
អង្គុញដើមយាងម្ដេចយ៉ាងនោះ

១— សត្វតាវើ ។ ២— លាន់ឮខ្ទររំពង ។

ឲ្យគេបោះតាំងស្រស់ដុតដូច្នេះ ៗ
យានអើយយានទៅសានកម្មយ៉ាងណា
បានជាមកវេទនាឲ្យក្ទើនផេះ
ឈើឯទៀតមិនដូចឈើយាននេះ
បើតាមរិះឈើនេះចុះតម្រា ៗ
សមណៈមានទ្រព្យសិកាក្លួន
ស្រីមានខ្លួនប្រុសក្លួនដោយកាមា
ព្រឹក្សាជាតិយ៉ាប់យ៉ឺនព្រោះផ្លែផ្កា
ត្រីអាំងមានទើបធ្លាមកយាយី ៗ
យានឯងយ៉ាប់ព្រោះមានជ័រទឹកនៅ
បានជាត្រូវកំដៅព្រះអគ្គី
ឈើឯទៀតឥតជ័រគេខ្ចី
គ្មាននរណាយាយីដូចយានឯង ៗ
ទព្រឹក្សាត្រូវការមិនថាអ្វី
កើតសម្រាប់ផែនដីប្រាកដស្ដែង
ដូចរូបកាយសង្ខារគេតុបតែង
មិនផុតការគ្នាឯងតែងអាស្រ័យ ៗ

ឲព្រឹក្សាលតានាមប្លែក ៗ
បុពណាចែកបេះឲ្យឈ្មោះទីទៃ
គោតហ្ន៊លោកបុពណាបេះកែខៃ
ឲ្យនាមសព្វឈើព្រៃគ្រាន់កំណត់ ៗ
វេះផ្លូវទៅពីសៀមពបឯង
ដល់កន្លែងមុខនាគនគរវត្ត
បានមួយរយសែសិបសិនទៀងទាត់
សេសប្រាំសិនសន្ទូតកត់មាត្រា ៗ
លុះដើរដល់ជ្រៃជំត្រសុមម្លប់
បបួលគ្នាចូលឈប់ម្លប់សាខា
សម្រាកញើសរំហើយដោយរាក់តា
ព្រះសុរិយោជ្រេសែនឱនោទ័យ ៗ
ទើបនាំគ្នាបរលើបាកទីនោះ
ក័ក្រ្កាឆ្ពោះតម្រង់ត្រង់ដល់ញ
មន្ទីរថ្មីលោកតាំងជារំងជ័យ
សម្រាប់ទីក្សត្រថ្ងៃព្រះទ្រង់សក្តិ ៗ
លោកសក្តិបីស្តីទីព្រះអាជ្ញា

ជាឥស្សរាក្នុងការព្រះដំណាក់
ចៅហ្វាយខែត្រសៀមរាបបំរុងសក្តិ
ទទួលភ្នាក់ងារកេណ្ឌរាស្ត្រតែងផ្លូវ ៗ
ចៅហ្វាយខែត្រព្រះដំបងរ៉ាប់(១)សំអាង
កេណ្ឌពួកជាងរចនាការក្នុងក្រៅ
ចៅហ្វាយស្រុកគ្រប់ខែត្រគ្រប់លំនៅ
សឹងចុះត្រូវកំណែនការទីទៃ ៗ
គឺឧកញ៉ាស្វាយបេកចំណែកមុខ
និងឧកញ៉ាក្នុំស្រុក ខែត្រជើងព្រៃ
រួមឧកញ៉ាសួរសក្តិសោភ័ណក្រៃ
ត្រូវធ្វើតម្វាជ័យដំណាក់ធំ ៗ
កេណ្ឌឧកញ៉ាក្រឡាញ់បព្វាលមុខ
រួមឧកញ៉ាខែត្រស្រុកសូទ្រនិគម
ត្រូវកេងខោលកេងសែក(២)បែកតាមមុម
ឯកេងថែវអមជុំត្រូវកម្ទី ៗ

១— រ៉ាប់ = ជានា, រ៉ាប់រង, ទទួលបន្ទុក ។ ២— កេងខោល = កេងល្ហោង ឬកេងសេងរបាំងផ្សេង ៗ ។ កេងសែក = សំណាក់ដែលមានទឹកត្រាំនិងលប់លាងមុខជាដើម ។

គឺស្រុកពួកស្រុកមោនស្រុកត្នោតផង
ទាំងទឹកជោរបាត់ដំបងមង្គលបូរី
ឯឧកញ៉ាមង្គលធរនិន្ទថ្មី
ត្រូវបើកត្រីអង្ករបែកគ្រប់កង ៗ
ទៅហ្វាយខែត្រសៀមពបនាយកំណែន
ឲ្យកោះកេណ្ឌរទេះជាងរយហោង
កេណ្ឌទូកធំសាមសិបមាននាយកង
ចាំពប់រងចូលចេញខាងជើងទឹក ៗ
កេណ្ឌគូលីមួយរយប្រចាំនៅ
តែការជល់គេហៅចុះបែរគ្រឹក
ពស្ត្រសៀមពបរវល់ខ្វល់ពន្ទឹក
ទាំងជើងគោកជើងទឹកពេញគ្រប់ជាន ៗ
ខាងការហ័សកេណ្ឌសេះហាសិបបាយ
សម្រាប់នាយ ៗ ដើរពុំបាន
តាំងរថាសារថីព្រះពជយាន
ប្រចាំព៉ក្សត្រក្សាន្តស្ដេចយានជល់ ៗ

ពួកក្រមការចាត់ការព្រះពន្លា
សឹងប្រកួតអួតគ្នាគ្រប់មណ្ឌល
ជ្រើសតែជាងស្ទាត់ ៗ ហត្ថកោសល្យ
ធ្វើមិនធ្វល់ក្នុងការដំណាក់ថ្មី ៗ
ឯរោងលោកកុម្មីសែរតាំងខាងស្ពាន
មានទាហានតាំងរានចាំប្រក្រតី
បន្ទាប់តរោងផ្ញុំក្រុមមន្ត្រី
កណ្ដាលលោកសក្ដិបីរាជអាជ្ញា ៗ
ចុងខាងត្បូងគឺរោងលោកចៅហ្វាយ
ព្រះដំបងតាំងរាយប្រជិតគ្នា
លោកសក្ដិបីនាយត្រួតលើព្រះពញា
ឲ្យកេណ្ឌតាមយសាបណ្ដាសក្ដិ ៗ
សឹងប្រដាប់ឈើស្រស់របស់ព្រៃ
ក្រងជាកួងមាលៃបំពេនពាក់
ចងសំយុងជាកួងរបៃថ្នាក់
កែមចម្លាក់មើលចម្លែកក្នែកលោកិយ៍ ៗ
ឯពួកចិនតែងខាងហាងដាក់ផ្សារ

មានទំនិញសព្វប្រការគ្មានខ្វះអ្វី
ខ្វះតាំងរានលក់ភោជន៍ក័ស្តុចំណី
ស្លា បារី កាហ្វេ តែ នំប៉័ង ។
ខាងពួកខ្មែរអ្នកស្រុកលក់ចេកស្ងោរ
នំចាក់គោរនំផាលន្ទូរនំបាំង
ខ្វះក៏លក់នំបញ្ចុកលតបាយអាំង
ខ្វះក៏តាំងរានមី រានសុព ។
បណ្តាពួកអ្នកទៅនគរវត្ត
ពុំមានអត់នឹងស្បៀងលៀងដីរ៉
មានតែប្រាក់ក៏ទិញបានគោក្តា
សែនមហាលោះលាយសប្បាយក្រៃ ។
ដោយទីនោះធ្លាក់ទៅជាសមសាន
លោកមករៀបជាស្ថា'នព្រះរាំងជ័យ
មើលសព្រោតក្ដីជ្រះជាស ទាំងព្រៃ
ហាក់មឿងមានក្សត្រថ្ងៃគង់ប្រក្រតី ។
ឯខាងពួកបារាំងតាំងសាងតឹក ១)

---

១ — គ្រឹះស្ពានសំខាន់ៗ (ពាក្យប្រើតាមសៀម) ។

មើលភីលឹក(១)ប្រក់សឹងស័ក្កសី
ផញ្ញាំងលាបបាយអពណ៌លឿងខ្ចី
គ្រឹះពីដីផ្ទៃស្មើល្អបវរ ។
ផ្ទះនោះឯងថែងក៏ប់ទីប្រជុំ
លោកគូវៃណើរជាធំព្រៃនគរ
លោកអញ្ជើញមកដោយក្ដីសាទរ
សមោសរពជគារនគរវត្ត ។
ខ្ញុំបាទយល់ទីស្ថានលោកតែងថ្មី
ទឹកសរសើរបារមីព្រះបមក្សត្រ
គ្រាន់តែយានមួយគ្រាក៏កើតបាត់
ទីព្រៃស្ងាត់ក្លាយកើតជាវាំងស្ថាន ។
ឱព្រះគុណប្រកបដោយបុណ្យក្រៃ
លើសនិស្ស័យយើងពុំប្រមាណបាន
ខំឧស្សាហ៍យានមកទីបុរាណ
ឲ្យព្រៃប្រែជាស្ថានបូរីរតន៍ ។

---

១. ភីលឹក = ប្លែក, គួរឱ្យឆ្ងល់ ។

មើលកសិណ(១)យល់ក្រសែដលេសាយ(២)
រាលវែងឆ្ងាយឧបអមនគរវត្ត
លោកជីកធ្វើជាគូរាំងស្អាតស្អាត់
មានបង្អាត់ខឿនខណ្ឌខាត់ពៃរី(៣) ។
គន់គង្គាក្រសិន្ធុវែងវឹង
ខឿនសុទ្ធសឹងថ្មជាជាសនាទី
ឆ្លាក់ជារូបក្បាច់ហូតហៀនពដីរ៍
ជណ្ដើរគោចក្បាច់ភ្ញីដកបន្ទន់បែង ។
កណ្ដាលហាន់មានស្ពានថ្មជាជាស
បំនួនក្រាស់ជាងសិនសែនគួរស្ញែង
តែកំណត់ទទឹងនឹងប្រវែង
មានក្នុងក្បួនល៉ាយថែងលោះកបែងទុក ។
ខាងចុងស្ពានមានឆ្លាជាបីផ្លូវ

១— កសិណ = គូទឹក, ស្រះដែលជីកធ្វើជាកំពែងជាគោលបារីក ២— ប្រឡាយទឹកយ៉ាងវែងអន្លាយ ។
៣— ខាត់ពៃរី = ការពារសត្រូវ ។ កាត់សត្រូវ ។

មានរូបគោឈរនៅគ្រប់មុមមុខ
គោសិលាខ្លះនៅពុំទាន់ពុក
ខ្លះបែកមុខបាក់គ្រាញពិការកាយ ។
អនិច្ចាគោថ្មលោកកសាង
មើលថាថាង(១)យ៉ាងរស់ស្កុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ
ស្តាយអើយស្តាយមិនគួរមកពិការ ។
មានអ្នកព្រៃផ្សៃឥតគំនិត
ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឲ្យខូងខូចខាតសាច់បង់អសារ
មិនស្តាយការស្នាដៃបុរាណសោះ ។
ឱគោអើយគោឈរមិនមើលមៀង
មកឲ្យគេសំលៀងខ្នងគោចុះ
ម្តេចមិនខឹងខាំវាសំលៀងនោះ
ឲ្យវាលុះក្តីមរណ៍យក៍វាទៅ ។
អាណាអើយបំផ្លាញរូបគោលោក

១—ថាថាង = កាយវិការ, ឫកពា ។

គ្មានប្រយោគឲ្យយល់ការរាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ
មកសត្រូវបំផ្លាញរបស់លោក ។
គន់ៗ ស្ថានស្ពានថ្មតប្រជិត
ជាក្ពារថ្មជាសជិតប្រកិតគោក
ទោះដំរីបរជាន់ក៏គ្មានយោក
ឥឡូវជ្រោកស្រុតខ្លះតែដើរបាន ។
បង្កាន់ដៃឆ្នៃរូបរាំសុក្រី(១)
ជប់សិរសីដូចស្និតជិតជុំប្រាណ
លើកពពារឡើងពក្លាក់ហាក់ហៅហាន
សំដែងប្រាណប្រួញរូបជាមួយគ្នា ។
មើលនាគពជអធំ អាចអំណាចស្ញែង
ខ្លួនក៏វែងក្បាលក៏វក់តាមទ្វាព
លូនលើស្ពានមានដើងកល់គង្គា
កន្ទុយបែកញែកគ្នាតាមផ្លូវ ។
ទរូបរាំសុក្រីឥតក្រែងគ្រុឌ

១— នាគជាទីតាំងព្រះនារាយណ៍ងទីនេះគឺ នាគ) ។

តាំងសម្តែងរឹទ្ធិឫទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ
គង់ស្ទុះទៅជ្រកក្នុងកសិណនេះ ៗ
នាគអើយនាគបាសាណបុកណសាង
ពីដើមយ៉ាងល្អឯកដូចម្តេចអេះ
ឥឡូវនាគងាកធ្លាក់បាក់របេះ
ឃើញតែពងយ៉ាងនេះអស់លំអរ ៗ
ខ្លួនក៏ឃ្លាតក្បាលក៏ឃ្លៀងទៅដោយខ្លួន
ឃើញតែក្បួនជើងទៀនប្រចាំទ្រ
ស្តាយអើយស្តាយស្នាដៃលោកតែងមក់
មិនតាំងតថាវរៈឲ្យវែងទៅ ៗ
ឱអនិច្ចាសង្ខារនាគាថ្ម
ហ្មាយតស្ថិតស្ថេរចីរកាលទៅ
នេះពុំទាន់ប៉ុន្មានមកហ្មងសៅ
មករុះកយធ្លាយទៅទីទៃផ្តាស់ ៗ
មែនហ្ន៎សព្វសង្ខារក្នុងលោកិយ៍
មិនថាអ្វីតែកើតមកគង់វិនាស

ចុះត្រៃលក្ខណ៍ជាក់យ៉ាងពុទ្ធប្រកាស
សង្ខារចាស់គង់ផ្លាស់ទៅទីទៃ ៗ
អម្បាលឫគង់ប្រេះបេះបាន
ចំណាន់បើរូបប្រាណយើងសព្វថ្ងៃ
នឹងបានជាតិខ្លឹមសារឯណានៃ
គង់បន្ទោរដោយដៃពេគបិណ្ឌា(១) ៗ
កើតជាកាយគង់ធ្លាយសូន្យដីរី
បំពេញព្រះធរណីតែកល់គ្នា
គួរនឿយណាយបង្អន់ក្លើងលោកា
យកនាគានគរវត្តសង្កត់កាយ ៗ
ខ្ញុំពិនិត្យគិតផ្លូវព្រះត្រៃលក្ខណ៍
ចិត្តមិនធ្លាក់ឲ្យអារម្មណ៍ហ្មាយ
នៅតែស្លុះម្ដង ៗ ដល់ធោមធាយ
ព្រោះឃ្លាតឆ្ងាយក្រែងឃ្លៀងលំអៀងទៅ ៗ
ឧចិត្តខ្ញុំលោកិយដូចពានរ
មិនដែលឈឹងនឹងឈរឲ្យនឹងនៅ

ឃើញឯណោះទឹកឯណោះមិនចុះផ្លូវ
ថាតែក្រៅក្នុងមិនត្រេបក្វេចក្ដីត្រេក
លុះដើរដល់កេងទងខ្វានទ្វារប្រាង្គ
របៀងខាងយ៉ាងខណ្ឌកន្យែងយ៉ែក
តួកណ្ដាលមុខដាច់ជាបួនប៉ែក
មានយ៉សែកបែកពុះជាពីរផ្លូវ ។
ប្រាង្គកណ្ដាលមានរូបទេពសិលា
គឺអ្នកតាមហាពជប្រចាំនៅ
បួនព្រះករកាន់គ្រឿងក្វឹសន្ទៅ
មើល ៗ ទៅគួរសម្បើមស្បើមហិមា ។
ពួកអ្នកព្រែពប់អានជាទេព្រក្ស
យកក្រជាសមាសប្រាក់អុជបូជា
បន់អ្នកតាមហាពជរឿងរឹទ្ធា
សូមឲ្យកើតលាភស្រីសួស្ដី ។
ខ្ញុំយល់រូបអ្នកតាហត្ថាសាយ
ទំនងព្រះនារាយណ៍រឿងរង្សី
ព្រោះបុកណកពប់អានព្រះសូលី

ឥស្សរាធិបតីតាំងជាមុខ ។
ពួកអ្នកព្រៃពុំស្គាល់យល់អំណាច
នាំគ្នាហៅមហារាជទៅតាំងស្រុក
ឲព្រះនារាយណ៍រឿងតេជវិសេសសុខ
ផ្ចាញ់មារទេសមុខបានសុខា ។
មើលដំណាក់ប្រាង្គដាក់ព្រះនារាយណ៍
កំពូលបាក់ធ្លាក់ធ្លាយធ្លុះសុរិយា
ឥឡូវមានគេធ្វើជាបញ្ហា
ប្រក់ក្បឿងយើងធម្មតាការក្រៀងខ្យល់ ។
ទ្វារខាងត្បូងមានគ្រឹះប្ញសដល់ដី
បររទេះសាលីទាំងសកល
ទោះដំរីទាំងក្បូបក៏តតទាល់
ចុងផ្លូវជល់មុខនាគជាដើមព្រ័ត្រ ។
ផុតកេងខងរំលងខ្វាងទ្វារប្រាង្គ
លោកសំអាងសាងជាកំពែងព័ទ្ធ
តាមកសិណឡោមជុំនគរវត្ត
លោកកំណត់ទ្វារចេញជាប្អូនជាន ។

ចូលទ្វារប្រាង្គចេញខាងទិសបូព៌ា
មានថ្នល់ធ្លាទៅត្រង់មុខព្រះលាន
លោកវិចិត្រដោយថ្មកជាស្ពាន
សងខាងមានរូបនាគបង្កាន់ដៃ ។
រយៈផ្លូវសិនមួយមានផ្លូវញែក
ជាពីរប៉ែកបែកចុះទៅទីទៃ
ដល់កណ្តាលមានប្រាង្គខាងស្តាំដៃ
ពួកអ្នកព្រៃហៅថា៖ពេងក្រយា ។
ប្រាង្គខាងឆ្វេងគេហៅពេងចំណី
មើលគួរបីសមពាក្យអ្នកព្រៃថា
មានផ្លូវចុះពីថ្នល់ដល់ដូចគ្នា
តែឥឡូវទៅជាព្រៃដុះជិត ។
ពេងព្រះស្វាយធ្វើដោយសិលាក្នុំ
តាំងជាមុមមុខបីជាបីស្និត
ឥតកំពូលមានដំបូលលោកវិចិត្រ
យ៉ាងសន្ធិតឥតកិតកាពស្មើផ្ទៃ ។
ទុពេងគ្រួមិនគួរមកផុះធ្លាយ

បាក់ខ្ចាត់ខ្ចាយអន្តរាយដោយពួរព្រៃ
គ្រាន់ទឹងចូលទៅមើលក៏ស្តុកក្រៃ
សែនអាល័យស្តាយពេងខ្ទមអសារ ។
លុះដើរដល់មណ្ឌលផ្ទះបាំង
លោកមកតាំងកសាងប្រាង្គបូជា
ឈ្មោះមោនសៀរកុម្ម៉ៃជាមេការ
ទៅភ្នាក់ងារទទួលជួសប្រាង្គណ៍ស្ថាន ។
លោកឲ្យដីកអាចម៍ដីដែលលុបថ្នល់
ដរាបដល់គ្រឹះថ្នល់ពីបុរាណ
ថ្មឯណាដែលបាក់ធ្លាក់ចាកស្ថាន
លោកឲ្យដាក់តាមដានសណ្ឋានចាស់ ។
លោកមោនសៀរកុម្ម៉ៃដៃបាំង
យកសីមាំងលាបផ្ទាប់ដូចក្រដាស
ឯណាស្លែចាប់ខ្លាំងមើលមិនច្បាស់
លោកឲ្យលាងបោសប្រាសសំអាតចេញ ។
ពួកគូលីស៊ីឈ្នួលជួលធ្វើការ

កាប់ឈើធ្វើផាផាក់ពាសពេញ
ខ្លះបោសផ្លាថ្នល់រលីងធ័ញ
អ្នកចូលចេញមិនមានដិតធូលី ៗ
ខ្ញុំដើរដល់យល់ថ្នល់លោកសំអាត
ឃើញពួកជាតិខ្មែរយើងជាគូលី
ទឹកអាណិតជាតិខ្មែរក្រដល់ទី
ទទួលការគូលីស៊ីឈ្នួលគេ ៗ
គន់រូបពងទុពិលពោះកំប៉េះ
សក់ក្រញាញ់ខ្មៅក្រញោះខ្អែះដូចកេ
តាំងស្លៀកពាក់សំពត់ក៏ខុសគេ
ឲខ្មែរទម្ដេចខុសនឹងយើងម៉្លេះ ៗ
ឬពួកនេះជាជាតិសម្រែគួយ
អ្នកងារស្លួយលេខវត្តនគរនេះ
ឬជាព្នងដែរគេកេណ្ឌរែះ
បានជាប្លែកយ៉ាងនេះគួរអនិច្ចា ៗ
លុះដើរដល់បណ្ដាលទីកនហាល

ថ្មជាជាលក្រាលសឹងក្ដារសិលា
ផ្ទៃពីដីពេជ្រួតត្របកផ្កា
រៀបជាសារពើរស្បូត្រ(១)ថ្នាក់ ៗ ៗ
មានសរសេរថ្មឈូកជាញាកពេញ
តាំងជុំវិញមានក្បាច់រំលេចជាក់
មានជណ្ដើរកាប់ឡើងជាថ្នាក់ ៗ
បីប្រច័ក្ខឡើងចូលព្រះប្រាង្គស្ថាន ៗ
ផ្ទៃកនហាលកាលដើមហោះសំណ
លុះត ៗ ដល់យើងអន្តរធាន
ប៉ាក់សំណនៅតែថ្មក្រាលជាលាន
របៀបកនកបណៃនសែនកិរ្យ ៗ
គន់ប្រាសាទស្អាតប្រសើរដំណើរប្រាង្គ
កំពូល ៥ បួនខាងខ្ពស់ត្រសុំ
ហ៊ានរួត ៗ ពល់ជាន់ជាពាន់ជុំ
ប្រាសាទធំតាំងកណ្ដាលត្រដោមជុង ៗ

១— សារពើស្បូត្រ = ឈ្មោះក្បាច់របតាមានសណ្ឋានបេក់បីផ្លែគ ។

រួតពីដីបីជាន់កេងទងជុំ
របៀងមុមមុខជាប់ក្បាច់រលង់
ជាហួតហៀនវៀនរាំងកញ្ចាំងចុង
ឈូកសម្បាកចែកសម្បុងជាខាន់ ៗ ៗ
ក្បាច់រងស្បូវទេពប្រណម្យដៃប្រណិត
លួសប្រកបលាយប្រកិតក្បីវល្លិវ័ណ្ណ
បែរគាប៉ាំងកើតស្និតរយពាន់
របៀងខាន់របៀបខាត់បាត់ស្មើគ្នា ៗ
ហោជាងឆ្លាក់រូបយក្ខជាក់ពានរ
យុទ្ធនារីករជាកោលា
រូបកហូបៀមហៀនហង្សពាំផ្កា
យក្ខទេវតាទាញព្រ័ត្រវ័ទ្ធគិរិន្ទ ៗ
មេក្របទ្វារបង្អួចក្បាច់បេក
លកក្របកផ្ដាប់មុខដូចគេមិន
ផ្ទៃគារផ្ទៃរឆ្លាក់រូបកដទេវិន្ទ
តយុទ្ធឥន៍អសុរិន្ទកដចិត្រា ៗ

ដញ្ញាំងទ្វារធ្លាក់ដាទេពរបាំ
ក្រោយលំនាំឈរកំក្បាច់កាច់ផ្កា
ខ្លះបួងសក់ខ្ពក់បីបងដដា
ខ្លះសំយាកកេសាសិតក្របាំង ៗ
ខ្លះពាក់មកុដកំពូលបញ្ចាសិង្គ
បែមុខក្រឡឹងភាពកញ្ចាំង
សូរងកងអង្គន់ព្រះហត្ថ
ស្លៀកសម្ពុយថ្នក់បាំងក្រោមនាភី ៗ
បង្កេះរៀវដង្គន់ព៉ប់មួយក្តាប់ដៃ
មើលវិសេសសុទ្ធវិស័យសមឥន្ទ្រិយ៍
សុតនក្បុំសមក្បួននួនមាលី
ភាពនរេតកេទនារីទីស្នេហា ៗ
មានប្រុសយើងក្ញើងកាគក់ពេលខ្វាំង
ទៅអង្គែល “មុំសំ” នាងសិលា
ឡើងលេង់សឹករលើងទាំងរូបា
គេសញ្ញាហៅថាស្រីមានលក្ខណ៍ ៗ
មើលមណ្ឌលពេងទងចំនងស៊ុម

រួតពីដីបីជាន់កោងទងជុំ
របៀងមុមមុខជាប់ក្បាច់រលង់
ជាហ្លួតហៀនវៀនរាំងកញ្ចាំងបុង
ឈូកសម្បាកចែកសម្បុងជាខាន់ ៗ ។
ក្បាច់រងស្បូវទេពប្រណម្យដៃប្រណិត
ល្អសប្រកបលាយប្រកិតក្បៀវល្ងវណ្ណ
បៃរកាប៉ាំងរកិតស្និតរយពាន់
របៀងខាន់របៀបខាត់បាត់ស្មើគ្នា ។
ហោជាងធ្លាក់រូបយក្ខដាក់ពានរ
យុទ្ធនាវឹករវជាគោលា
រូបកហូបៀមហៀនហង្សពាំផ្កា
យក្ខទេវតាទាញព្រ័ត្រវ័ទ្ធគីរិន្ទ ។
មេក្របទ្វារបង្អួចក្បាច់របក
លកក្រូបកផ្កាប់មុខដូចគេមិន
ផ្តែគ្នាផ្តែរធ្លាក់រូបពដទេវិន្ទ
តយុទ្ធនឹងអសុរិន្ទកដចិត្រា ។

ជញ្ជាំងទ្វារធ្លាក់ជាទេពរបាំ
ក្រោយលំនាំឈរកំក្បាច់កាច់ផ្កា
ខ្លះបួងសក់ខ្នក់បីបង់ជដា
ខ្លះសំយាកកេសាសិតក្របាំង ៗ
ខ្លះពាក់មកុដកំពូលបញ្ចាសិង្គ
បែមុខក្រឡឹងភាពកញ្ចាំង
ស្ទូរងកងអង្កន់ព្រះហត្ថ
ស្លៀកសម្ពុយថ្នក់បាំងក្រោមនាភី ៗ
បង្កេះរៀវដង្គន់ព៉ប់មួយក្តាប់ដៃ
មើលវិសេសសុទ្ធវិស័យសមឥន្ទ្រិយ៍
សុតនក្បំសមក្បួននួនមាលី
ភាពនរេតកេទនារីទីស្នេហា ៗ
មានប្រុសយើងក្លើងកគក់ពេលខ្លាំង
ទៅអង្អែល “មំសំ” នាងសិលា
ឡើងលេង់សឹកលើងទាំងរូបា
គេសញ្ញាហៅថាស្រីមានលក្ខណ៍ ៗ
មើលមណ្ឌលពេងទង់ទំនង់ស៊ុម

ជញ្ជាំងជុំសឹងជិតជាចម្លាក់
ជារូបរឿងរាមកេរ្តិ៍គឺរាមលក្ស្មណ៍
ចំបាំងនឹងយក្សក្រុងរាពណាសូរ ៗ
ស្វាប្រចាក់យក្សប្រចាប់ក៉ប់រងគ្នា
ស្វាក្រទីយក្សក្រទាកាប់ផ្លាស់ប្តូរ
យក្សប្រជិតស្វាប្រជាប់ចាប់កំពូល
ស្វាប្រដាល់យក្សដួលដេកក្សិណក្ស័យ ៗ
គន់គំនូររឿងរាមសង្គ្រាមយក្ស
ជាអនគ្ឃ៍មើលអនេកអនន្តក្រៃ
ជ្រុងទក្សិណគួរកាលសហស្សនៃយ
គន់ទៅឯកៃឡាសវិមានចន្ទ ៗ
កៃឡាសផ្អៀងផៀងធ្លាក់ព្រះសូលី
ប្រើក្រុងរាពណ៍អសុរីពជកុម្ភណ្ឌ
ដៃម្ភៃមុខដប់រូបសកន្ទ

ឲ្យតម្រង់ប្រាង្គចន្ទកៃឡាសស្ថាន ៗ
រាពណានេរមិត្ររឹទ្ធសាហ័ស
តម្រង់ក្អំកៃឡាសឡើងត្រង់បាន

ព្រះឥសូរក៏ទ្រង់ព្រះរាជទាន
នាងមណ្ឌោកល្យាណជាភរិយា ។
ផ្ដែរខាងបូព៌ាគួរកាលសុគ្រីពយំ
អង្វរអង្គព្រះបរមរាមា
ឲ្យជួយផ្ចាញជីវិតនៃស្ដេចស្វា
ក្រុងពាលីជេដ្ឋាបច្ចាមិត្រ ។
ព្រះរាមក៏ប់ចាប់ធ្នូបូរថ្វែងសរ
បាញ់ពានរពាលីសូន្យជីវិត
គួរទាំងពួកនារីស្រីស្នំស្និទ្ធ
សោកអាណិតសែនអាណោចខ្លោចពាលី ។
ឯសុគ្រីពរទ្ធឹរទ្ធីបុត្រសុរិយោ
ក៏សោកានៅទៀបព្រះទែនទ័
អញ្ជើញអង្គរាមាចូលធានី
តាំងពិធីលើកសពពានរ ។
ឯជញ្ជាំងខាងត្បូងគួរព្យហបាទ
ដង្ហែអង្គនរនាថកេតុមាលា
លើកជាក្បួនព្យហយុទ្ធនា

គ្រប់គាសាចូលពឹងព្រះបារមី ។
ខ្ញុំគន់មើលព្រះកេតុគេបិទមាស
គង់លើអាសន៍កណ្ដាលពួកសេនិយ
សែនរុងរឿងថ្កើងបុណ្យព្រះចក្រី
ជាអស្ចារ្យផែនដីសកលអាយ ។
អង្គនេះឬគឺជាបរមក្សត្រ
គ្រង់សម្បត្តិឥន្ទប័តវិសេសសាយ
ទ្រង់សាងព្រះនគរវត្តដ៏ធេងធាយ
ស្ដេចលើកថ្វាយព្រះពុទ្ធឃោសា ។
កាលលោកទៅចម្លងព្រះគម្ពីរ
អំពីរាជធានីកោះលង្កា
វិលមកដល់ប្រទេសខេមរា
បរមក្សត្រានិមន្តឲ្យលោកនៅ ។
លើកប្រាង្គនេះប្រគេនជាមណ្ឌល
ទីតម្កល់ព្រះគម្ពីរគម្ពីរជ្រៅ
ពុទ្ធឃោសាចារ្យលោកគង់នៅ
បានជាហៅនគរវត្តដោយកំណត់ ។

ព្រោះប្រាង្គនេះពីដើមជានគរ
ដល់ក្រោយទ្រង់សាទរថ្វាយជាវត្ត
ពួកបុរីនាំគ្នាមកសន្មត
ហៅប្រាសាទនគរវត្តតាមបទមាន ។
ឱព្រះគុណព្រះកេតុមាលាក្សត្រ
ព្រះទ័យកាត់ពុំស្តាយព្រះរាជស្ថាន
ថ្វាយជាវត្តសូរេចស្តេចចេញឋាន
ទៅតាំងស្ថានព្រៃក្មេងបេងមាលា ។
ឥឡូវសូន្យព្រះយសឈ្មោះបាត់បង់
ឃើញតែរូបព្រះអង្គគង់ច្នេះណា
ខ្ញុំបាទយល់សរសើរព្រះចេស្តា
លើកហត្ថាបង្គំគុណក្សត្រថ្លៃ ។
គន់មើលព្រះកេតុមិនឆ្អែតក្តីសន្និះ
ឱប្រាង្គនេះមើលទៅផុតនិស្ស័យ
ឃើញឥឡូវគិតទៅអចិន្ត្រៃយ
មិនគួរទៅជាព្រៃសូន្យអសារ ។

យ៉ាងពីដើមមនុស្សច្រើនចំរើនបេះ
បានជាធ្វើប្រាង្គណ៍នេះគួរអស្ចារ្យ
ស្នាដៃធ្វើមើលស្មើព្រះពិស្ណុការ
តថ្មដាស្បូលដែកសែកគ្នាជាប់ ៗ
បោះក្នុងថ្មតផ្ចិតរលាយសាច់
ដល់យូរមកដែករេចរោយច្រេះចាប់
នៅតែព្រង់អ្នកព្រៃប្រាជ្ញាអាប់
ថាស្នាមម្រាមដៃចាប់មនុស្សបុរាណ ៗ
ខ្លះសង្ស័យថាដៃព្រះឥន្ទ្រប្រើ
ឲ្យវិស្សកម្មធ្វើថ្វាយក្សត្រក្សាន្ត
ខ្ញុំគន់ ៗ មើលសព្វមន្ទីរស្ថាន
មិនសមដៃមយរ៉ានលោកធ្វើឡើយ ៗ
ព្រះឥន្ទ្រអ្វីមកធ្វើមិនឲ្យស្រេច
មើលទៅក្បាច់ខុសគ្នាណាលោកអើយ
ខ្លះអាក្រក់ខ្លះល្អមិនស្មើឡើយ
បើព្រះឥន្ទ្រធ្វើហើយគង់ស្មើគ្នា ៗ
មួយវិញទៀតវិស័យទេពនិម្មិត

ធ្វើដោយរឹទ្ធគិតថ្វាយស្តេចអង្គណា
តែស្តេចនោះលុះអស់ព្រះជន្មា
ទីនិម្មិតទៅជាផែនដីវិញ ។
នេះប្រាសាទនគរនៅជាគឹ
នឹងថារឹទ្ធិនោះប្កយ៉ាងនេះមិញ
បើរឹទ្ធិមែនម្ល៉េះសមលើងធិញ
ទីនេះមិញក៏ពេញទៅដោយព្រៃ ។
សង្ស័យថ្វីនឹងដុំថ្មធំ ៗ
គេលើកយកទៅផ្គុំបានទាំងផ្ទៃ
គឺគេប្រើដោយយន្ត៉ការវៃ
នឹងបានប្រើដោយដៃនោះក៏ទេ ។
វិស័យជាងគេបេះគ្នាគេច្រើន
ស្តេចចំរើនដោយបុណ្យពីបុព្វេ
នឹងធ្វើអ្វីក៏ស្រេចចំណោះគេ
កុំទៅគ្នេថាអង្គព្រះឥន្ទ្រសាង ។
មានអ្នកខ្លះចូលចិត្តថាដីពិត
គឺគេដុតយ៉ាងឥដ្ឋជាថ្មប្រាង្គណ៍

ព្រោះឃើញទឹកសិណដំនៅខាង
ទំនងយ៉ាងយកដីកសិណនោះ ។
ឧហ្ន៎ជាតិអ្នកខ្លៅជៅមិនចំ
ម្តេចមិនមើលបែបពុម្ពតូចធំហ្នោះ
មែនបើដីគេធ្វើមានពុម្ពនោះ
គង់ប៉ុនគ្នាអស់នោះមិនហ្នោះឬ ។
នេះមិនមែនប៉ុនគ្នាជាបែបពុម្ព
ខ្លះក៏ធំខ្លះក៏តូចនៅជាគឺ
បុកណាស៊ីធោតម៉្វះមិនដែលត្រ
មកប្រឹងធ្វើដុំធំឲ្យធ្ងន់ក្រៃ ។
បើយ៉ាងថ្មបាយក្រៀមនោះយល់មែន
ព្រោះផ្ទៃផែនស្មើគ្នាទាំងអស់នៃ
ឯថ្មផុកអ្នកស្រុកកុំសង្ស័យ
គឺស៊ីមង្ត៍ថ្មព្រៃយកពីក្រៅ ។
បើមិនជឿអញ្ជើញទៅមើលឋាន
កុំខាងលើសឹងមានបំណាំងនៅ

ទាំងថ្មហ៊ុបថ្មជាប់គរតាមផ្លូវ
មានគេទៅបានឃើញជាអស្ចារ្យ ៗ
ខ្ញុំគន់មើលគំនូរគូរជញ្ជាំង
លើសកម្លាំងនឹងតែងឲ្យពិស្ដារ
វិលត្រឡប់ទៅមើលជាន់កណ្ដាល
ឃើញព្រះពេងជ្រះប្រាលក្រសាលលន់ ៗ
ជើងសសរឆ្លាក់រូបឥសីសិទ្ធិ
អង្គុយបត់ជើងបិទប្រើសិទ្ធិមន្ត
ផ្ទៃសសរមានអក្សរប្រកាសបុណ្យ
ឲ្យមហាជនមើលដឹងដំណឹងទី ៗ
មានសកពដក្នុងពដស្ដេចជាន់ក្រោយ
ទ្រង់អំណោយសាងព្រះសាងគម្ពីរ
បានលែងមនុស្សជាខ្ញុំថ្វាយព្រះមុនី
តាំងសញ្ញីឈ្មោះទុកនៅមុខព្រះ ៗ
លើពិតានធ្នឹមខាត់បាត់ក្បាច់ផ្កាយ
ឈូកសាកយលាយលយលកល្បះៗ

គ្រឹះប្រជាប់ប្អូនប៉ែកចែកស្រឡះ
បន្ទោះជ្រុងមានស្រះជាប្អូនជាន ។
ឯស្រះនោះមានដក់ទឹកក្លៀងស្អាត
មច្ឆាជាតិអាស្រ័យនៅជាស្ថាន
ឥតបកព្រាំស្មៅព្រែកក់ផង់គ្មាន
ផ្ទៃសណ្ឋានប្អូនជ្រុងស្មើភាគគ្នា ។
លោកប្រជាប់ដោយថ្មកដល់បាទ
រលីងស្អាតសឹងរួតហួតពេជា
មានកើយកែវជណ្ដើរចុះគង្គា
មើលហាក់ជាស្ថានជ្រៅអណ្ដូងជ្រោះ ។
ខ្ញុំយល់ត្រីសង្ស័យហ្វូងមច្ឆា
មកពីណាទៅមានក្នុងស្រះនោះ
ស្រះលើប្រាង្គណ៍ផុតជាតិផែនដីសោះ
ទឹងមានជ្រោះហូរជ្រាបក៏គ្មានមុខ ។
ត្រីពួកនេះឧប្បត្តិកកើតឯងឬ
ឬមួយគឺគេយកមកលែងទុក

ខ្ញុំពិគ្រោះពុំឃើញមានទំនុក
សែនជាទុក្ខទឹងត្រើពេញអស្ចារ្យ ។
នឹងមានអ្វីជាចំណីអាស្រ័យបាន
បកសាកយក៏គ្មានជាអាហារ
មានតែស្លែដុះជាប់តាមថ្មជា
មើលអាការស្រះនោះជារណ្ដៅ ។
មានពេងទាំងបួនមុមជុំស្រះស្រង់
ខ្នងបង្កង់ជាប់គ្នាជាបួនផ្លូវ
ទ្វារឧត្តរមានជ្រុងក្នុងយ៉ាងជ្រៅ
នរណាទៅគោះទ្រូងព្ទស្នូរគង ។
មានអាការអស្ចារ្យទីនោះម៉្លេះ
បុកណារិះចេះធ្វើមានទំនង
ផ្ទៃកបស្មើពុំឃើញមានអ្វីផង
គោះតែទ្រូងព្ទគងស្នូរលាន់ ៗ ។
ពេងខាងត្បូងតម្កល់ព្រះបដិមា

ពុទ្ធបាទសាស្ដាហៅព្រះពាន់
អង្គខ្លះឈរខ្លះគង់សង្រួមខន្ធ
មានអរហន្តគង់គាល់ទាំងឆ្វេងស្ដាំ ៗ
អង្គព្រះខ្លះពិការបាក់សូរង
នៅតែដងអងកាយគង់ប្រចាំ
ព្រះខ្លះឈរកណ្ឌៀវសុីសាំ
បែកព្រះកាយបាក់ព្រះកាំស្រាំព្រះករ ៗ
មុខសជូបមានរូបច័ក្រពង្ស
ពីរព្រះអង្គគឺព្រះកេតុចៅនគរ
គង់ប្រណម្យបង្គំលើកព្រះករ
ទុនស្ទោះសរតគុណព្រះជិនស្រី ៗ
តរូបព្រះអង្គមួយដែលទ្រង់គ្រឿង
ពាក់ដជារុងរឿងរឿងរង្សី
ខ្ញុំពុំស្គាល់ព្រះនាមជាស្ដេចអ្វី
ពានចារឹកទឹងស្ដីជាស្ដេចណា ៗ
គន់ព្រះរូបចិត្តរួញកន្ទួញក្រាប

សិពេកបបង្គំព្រះសាស្តា
សូត្រសរសើរពុទ្ធគុណអនន្តា
ស្រេចទើបលាឡើងទៅជាន់ទី ៤ ។
បានខាងលើលោកធ្វើជាផ្ទៃពន
ជួរជុំមានសសរចេញដោយខ្លួន
សឹងក្រឡឹងជើងទៀនដ៏មាំមួន
មើលចំនួនប្រមាណជារយប្លាយ ។
ខាងឆ្វេងស្តាំមានកឹងតាំងពីរដាច់
ប្រកបក្បាច់ក្អក់ហៀនទិនលួសលាយ
តួកឹងនោះឥឡូវបាក់ធ្លាក់ធ្លាយ
គួរតែស្តាយកឹងថ្មអន្តរធាន ។
មើលបរិវេណចង្វាត់ព្រះប្រាង្គណ៍ធំ
ពេងទងជុំតាមជាន់គ្រប់ ៗ ជាន
មានញកញោចវួតពេជ្រតាមសណ្ឋាន
លើសប្រមាណនឹងរាស់កត់និយម ។
ជាន់ទីបួនប្រាង្គណ៍ ៤ ចតុរស

កំពូលខ្ពស់ស្មើគ្នាទាំង ៤ មុម
ខ្ញុំក៏ឡើងជាន់ ៥ ប្រាសាទធំ
ខ្ពស់ត្រសុមមើលត្រសែតអណ្ដែតចិត្ត ៗ
ភាពជណ្ដើរឡើងទៅក៏ខ្ពស់បោត
កាំនោះសោតតូច ៗ កាន់មិនស្និទ្ធ
បង្កាន់ដៃពុំមានទឹងយោងយិត
ខំកខិតឡើងទៅត្រាតែដល់ ៗ
គន់ជណ្ដើរឡើងទៅប្រាំបួនស្ពាន
ក្នុង ១ ជានតីរ ៗ ជុំមណ្ឌល
មានរួតថ្នាក់ល្បាក់ញកលោកតម្កល់
ជាពើងទល់ទាល់ដល់បង្កាន់លើ ៗ
តួប្រាង្គណ៍ទាំង ៥ យ៉ាងបេតិយ៍
រួតប្រាំបួនជ្រុងប្រាំបីជាស្មើ ៗ
ខឿនប្រដាប់ពេជ្ររួតច្រើនអទ្វើ
ត្របកស្មើជ្រុងមុមទាំងបួនជាន ៗ
មានទ្វារចូល ៤ ទិសតែគេទាស់

បិទជិតអស់មិនឲ្យចូលជិតបាន
ស្ពានជាអង្គព្រះឈរប្រតិស្ឋាន
ប្រចាំដានគ្រប់ទិសទាំង ៤ ទ្វារ ។
ខាងក្នុងប្រាង្គណ៍ យ៉ាងជាក់ព្រះមាសប្រាក់
ដែលបែកបាក់ធ្លាក់បង់អង្គពិការ
ឬរបស់ឯណាជាខ្ទឹមសារ
ក្រែងពួកចោរពួកមាររាយាយី ។
លោកមោនសៀរកុម្ម៉ៃទៅភ្ជាក់ឆារ
ឲ្យជាប់ទ្វារខាងត្បូងរូបព្រះជីវ៍
រំលើងអង្គព្រះទ្វារចេញចាកទី
រើយកព្រះខ្ទេចខ្ទីពីក្នុងប្រាង្គណ៍ ។
ខ្ញុំយល់អង្គព្រះទ្វារគេជាប់ផ្ដាច់
បាក់ស្បូវងរូបខ្ទេចមិនយល់រាង
ទឹកសង្វែកព្រះទ្វារគេរំលាង
ផុតរាងសាសនាព្រះទ្វារហើយ ។
ព្រះទ្វារទាំងបីលោកគង់សុខ
ពុំមានទុក្ខដូចអង្គព្រះត្បូងឡើយ

ឲព្រះត្បូងពីថ្ងៃនេះទៅមុខហើយ
រំលត់ខន្ធកាន់ត្រើយនិព្វានហោង ។
ខ្ញុំខំចូលទៅមើលកន្លែងគុក
ដែលគេតាំងព្រះទុកពុំឲ្យហួង
មើលមិនច្បាស់ព្រោះដះក្ងនម្តង ៗ
គឺប្រចៀវខ្មៀវកងរាឧច្ចារ ។
ទើបណាយថយចុះមកគ្រឹះធរណី
មើលពួកខ្មែរគូលីគេធ្វើការ
ជញ្ជូនយកអាចម៍ដីគឺឧច្ចារ
ចេញតាមទ្វារទិសបូព៌បង្ហូរគ្នា ។
គន់មណ្ឌលព្រះប្រាង្គណ៍ យ៉ាងល្វោលៗ
ពេលក្របីចូលក្រោលអស់សុរិយា
ខ្ញុំនាំគ្នាចុះមក កាន់វសុធា
ទៅរកទីនិទ្រានារាត្រី ។
លុះព្រឹកឡើងជាថ្ងៃមួយដណ្ដាប់

តិត្ថីជូនគំរប់ថ្ងៃសៅរ៍
លោកទៅហ្វាយក៏ដល់មណ្ឌលថ្មី
ថែងសេចក្តីថាថ្ងៃនេះហ្លួងដល់ ៗ
ខ្លួនលោកមកជាមុនដោយប្រញាប់
ទឹងអាលមកចាត់រ៉ប់ឯមណ្ឌល
ស្ដេចទឹងយាងមកតាមវិថីថ្នល់
កំណត់ម៉ោង ១១ ដល់ព្រះពន្លា ៗ
លុះនិយាយបានតិចលេចកៅរ៍
ជិះពាជីមកដល់ថែងកិច្ចា
ជំរបលោកសក្តិបីរដអាជ្ញា
ថាឲ្យរៀបព្រះពន្លាស្ដេចដល់ឆាប់ ៗ
លោកសក្តិបីឮច្នោះស្ទុះម្នីម្នា
ហៅពួកក្រុមយោធាជាប្រញាប់
ព្រមទាំងពួកខុនណាងគ្រប់សម្រាប់
ឲ្យរៀបខ្លួនឈររ៉ប់ព្រះចក្រី ៗ
ក្រុមទាហានក៏រៀបក្បួនស:លុត
ឈរអាវុធរន្ធិយាតាមថ្នល់ថ្មី

ពួកអ្នកស្រុកក៏ផ្អើលទាំងប្រុសស្រី
មកចាំមើលចក្រីមីរត្រៀបត្រា ៗ
ខ្លះក៏បីកូនតូចដឹកកូនធំ
អាតូចយំអាធំយិតស្ទើរដាច់ស្មា
ខ្លះក៏បាត់ប្អូនឃើញបងរកគ្នាធ្លា
ខ្លះឃើញយាយបាត់តាហៅគ្នាស៊ាន ៗ
ខ្ញុំគន់ ៗ អ្នកព្រៃចង់តែសើច
ត្រកូលទើបមើលខាតខុសសណ្ឋាន
ទាំងស្មៀកពាក់មិនសមនឹងខ្លួនប្រាណ
សែនរំខានទាស់ភ្នែកប្លែកគន្លង ៗ
មានយាយចាស់ខ្លះនោះរូបពត្លក់
ទៅពាក់ការទំពក់ដូចគេបង
ពាក់អង្កាំបារស្ពាន់ព័ន្ធកម្រង
មើលម្ដង ៗ បុះគន្លង៍ព្នងពិត ៗ ៗ
ឲអ្នកព្រៃតែងត្លួតតសំណាំ
ពុំចេះរៀបចេះចំតាមចារិត

ហេតុតែក្រពិត ៗ ទើបយ៉ាងនេះ
អនិច្ចា អ្នកក្រត្រដរមក ។
ខំប្របៀតជ្រៀតជ្រកទឹងគេប្នេះ
ខ្ញុំសម្តេចបានតិចលេចឃើញសេះ
ក្រមការគេជិះជាមគ្គុទេសក៍ ។
ឃើញព្រះទីនាំងកដរថពីរបេរ
ទិមអស្សុត្តរបរចូលដល់និវេសន៍
ទ្រង់យាងចុះលោកធំបាំងសែស
គំនាប់តាមប្រទេសវេណីក្រៅ ។
នាយទាហានក៏ស្រែកក្បួនសៈលុត
ចាប់អាវុធវន្ទីយាបញ្ឈរនៅ
ពួកនាម៉ឺនឱនកាយបង្គំទៅ
ទ្រង់ក៉ប់ផ្លូវបដិសណ្ឋារ ។
លោកសក្តិបីទទួលទីក៉ប់រង
ជាបាល័ដ្ឋទូលស្នងការនានា
គំនាប់ស្រេចឡើងកាន់ព្រះពន្លា
អស់ព្រះពញាហែឡើងដំណាក់ស្ពាន ។

ដល់ព្រះទែនស្តេចទ្រង់គង់កៅអី
លោកសក្តិបីអនុកូលទូលរ៉ាយង៉ាន
រឿងអ្នកទោសដែលជាប់ពីក្រៅស្តាន
កាលពីស្រុកមោះមានអាចោរខ្លាំង ៗ
លោកឲ្យចាប់ទាំងជាទាំងកាចបក
ព្រោះប្រាថ្នាដកយកស្បៀងកម្លាំង
នៃអាចោរទុច្ចរិតគិតតតាំង
កាត់កម្លាំងពួកចោរមិនឲ្យទៅ ៗ
បានជាកៀរគ្រួមកព្រះដំបង
ដាក់ទោសតាមទំនងដែលហ្លួងសៅ
ចាំស្រុករាបកាលណាទឹងលែងទៅ
ដល់ឥឡូវស្រុកក្សាន្តបានសុខា ៗ
គួរមេត្តាយ៉ាងណាស្រេចតែទ្រង់
ឬបន្ធង់ឈប់រង់មើលក្សិណក៏
ព្រះបមយសជ្រាបច្នោះទ្រង់មេត្តា
ឲ្យលើកកាត់ទោសាពួកអ្នកព្រៃ ៗ
សន្ទនាបានតិបតាមនុសន្ធ័

ឲ្យនិមន្តព្រះសង្ឃចូលថ្វាយជ័យ
ជយន្តោថ្វាយពរក្សត្រថ្វាថ្ងៃ
តាមនិស្ស័យវេណីពីបុរាណ ៗ
លោកសង្ឃយើងព្រះដំបងដប់អគ្គគត់
វិន័យធរដើមបទជាប្រធាន
រៀបព្រះអគ្គចូលកាន់ព្រះពំងស្ថាន
ទទួលក្តីពប់អានតបក្រា ៗ
ទើបថ្វាយព្រះជយន្តោពរកវ័ត
បំរើនពជពិភ័តមង្គលា
លុះចប់ស្រេចស្តេចត្រាស់សន្ទនា
ឲ្យសង្ឃលាទៅស្រុកតាមសម័យ ៗ
ព្រោះក្រែងជាប់វស្សាការសៅហ្មង
តាមទំនងសត្តាហប្រាំពីរថ្ងៃ
លោកសក្តិបីទទួលទូលកែខៃ
សូមអំណាចក្សត្រថ្ងៃយុំវស្សា ៗ
ក្រពង្សពុំទ្រង់ឲ្យអំណាច

ព្រះទ័យខ្លាចក្រែងខុសក្នុងសិក្ខា
តែសត្តាហព្រះដំបងហួសហើយណា
ហួងទឹកជាក្រែងលោកទើបដល់ថ្មី ៗ
ពុំជ្រាបហេតុព្រះសង្ឃព្រះដំបង
មកនៅចាំព៉ប់រងព្រះចក្រី
តាំងពីខ្ទើតមួយកើតចូលតិត្ថី
ដប់មួយសៅរ៍ហួសកំណត់ ៗ
សត្តាហបានតែប្រាំពីរថ្ងៃ
នេះហួសផុតនិស្ស័យសិក្ខាបទ
ថ្ងៃហួងដល់ដប់មួយកើតប្រាកដ
បើកំណត់សត្តាហហួសបួនថ្ងៃ ៗ
ហេតុដូច្នោះលោកសង្ឃព្រះដំបង
ដាច់វស្សាហើយហោងកុំសង្ស័យ
ខ្ញុំឮច្នោះអាណិតលោកពេកក្រៃ
ទម្លាស់ថ្ងៃគ្រង់កឋិនឃើញជាខាន ៗ
មួយអាណិតតែលោកវត្តនិវេសន៍
ជាប្រទេសមង្គលបូរីស្ថាន

ត្រូវទោសខុសកាលស្រុកកើតមោះមាន
ពួកទាហានបាញ់ចោរវេកល្បុក ៗ
លោកភ័យលោករត់ទៅនៅណោងបួ
ដល់ស្រុកពបនាំគ្រួសិស្សវិលស្រុក
លោកពជការថាលោកនាំកល្បុក
ឲ្យឃុំខ្លួនមកទុកព្រះដំបង ៗ
ឃាំងនៅវត្តពីកិតជាយូរខែ
ទម្រាំតែផុតទោសដែលមោះហ្មង
មិនដឹងជាថ្ងៃណាទឹងរួចហោង
សែនមួហ្មងចង់វិលទៅវត្តវិញ ៗ
រកឱកាសពុំបានរំខានចិត្ត
សែនអាណិតគិតទៅគួរតែម្នេញ
លុះឮការថាហ្លួងស្ដេចយាងចេញ
ចាកភ្នំពេញមកផ្ដុំនគរវត្ត ៗ
បានឱកាសដោយបេះក្បួនទ្នា
គាំជ្រួចក្បីគោហៀសម្រែកសត្វ
លោកវត្តលៀបមេការទីបាល័ដ្ឋ

លោកក៏ចាត់ឲ្យទៅជាមួយផង ។
ឲ្យលោកជួយការក្រីទីធ្វងបុណ្យ
ថ្វាយព្រះគុណ ជាគុណព្រះម្ចាស់ច្បង
បានឱកាសនឹងទូលសូមទោសហោង
នឹងបានវិលទៅគ្រងនិវេសន៍វិញ ។
លុះព្រហ្វឹងប្រោសលែងអ្នកទោសបង់
ទាំងបាសកលោកសង្ឃដូឈ្មោះមិញ
មួយលោកសង្ឃបីអង្គនៅភ្នំពេញ
ឲ្យវិលវិញមកនៅតាមដើមដាន ។
ចៅអធិការនិវេសន៍ក៏ស្បើយទុក្ខ
មានទឹកមុខរីករាយសប្បាយបាន
ថ្វាយព្រះពរលាអង្គចមក្សត្រក្សាន្ត
វិលទៅស្ថានទីលំនៅនៃអាត្មា ។
ចមកជាសន្ទនានឹងព្រះសង្ឃ
លុះសូរិយង្គរះរេជ្រេធាយា
សង្ឃទាំងឡាយក៏ថ្វាយព្រះពរលា

ព្រះពជាទ្រង់សោយដោយសម័យ ៗ
ស្តេចទ្រង់សោយព្រះស្ងោយវេលាជ្រេ
សូរេចសោយសុរិយេជ្រេសែងថ្ងៃ
ទ្រង់បន្ទុំសម្រាន្តព្រះហឫទ័យ
ពួកខាងណៃ ទាញផ្ទិតផាត់ថ្វាយទ្រង់ ៗ
សែនកំសាន្តក្សាន្តកិរម្យបរមនាថ
ព្រះពាយផាត់គន្ធជាតិពិដោរហ្វុង
មហោរីប្រគំបន្ទូនអង្គ
ចក្រពង្សទ្រង់ផ្ទុំកិរម្យខ្ទ័ន ៗ
លុះទិនករចរបែរជ្រេស្មើ
ព្រះចក្រីតើនចាកទៃនសុវណ្ណ
តែងព្រះអង្គចេញគង់ចុងពេងច័ន្ទ
ពួកកំណាន់គាល់ព៉ប់ស្តាប់ឧង្ការ ៗ
អស់ជំនុំមន្ត្រីកុង្សីយជំ
មកដល់ជុំចាត់ទីតាមមុខងារ
ក្រុមប៉ូលិសតាំងនៅប្រចាំទ្វារ

មើលត្រួតត្រារក្សាសត្រូវទ្រង់ ៗ
ពួកក្រុមពាំងលោកពាំងនាយចាងហ្វាង
ភ្នាក់ងារខាងស្តីការស្នំខាងក្នុង
ក្រុមតម្រួតនាយត្រួតព្រះដំរង្គ
លោកព្រះស្តេចស្តីការសង្ឃការី ៗ
អគ្គពជយមកពជក្រុមមឿង
សត្រីរឿងអាជ្ញាការផែនដី
ក្រឡាហោមចក្រីទីកុង្សយ
ភ្នាក់ងារស្តីតាមទីបតុស្តម្ភ ៗ
ឯខុនណាងខាងក្រៅណាកដំណែន
ភ្នាក់ងារតែងគ្រប់មុខទាំងតូចធំ
សឹងព្រមព្រៀងនៅរៀងពេនថែរធំ
តាមក្រុម ៗ ខ្ញុំពុំស្គាល់ទេលោកអើយ ៗ
គ្រាន់ទឹងតែងឲ្យគ្រប់ឈ្មោះអស់លោក
គិតប្រយោគទៅទៀតពុំបានឡើយ
ពេលក៏ជួនចុះយប់ព្រលប់ហើយ

ខ្ញុំក៏នឿយវិលទៅទីនិទ្រា ៗ
ពេលយប់នោះការហ្លួងទើបដល់ថ្មី
ក្រុមមន្ត្រីសម្រាកតែរាល់គ្នា
ពុំទាន់មានរាជការនឹងពណ៌នា
ខ្ញុំនិទ្រាលក់ទៅតាមសម័យ ៗ
លុះព្រឹកឡើង ១២ ថ្ងៃអាទិត្យ
ចមបពិត្រព្រះកែវហ្វាសុឡាឡៃ
ស្តេចរៀបគ្រឿងពលីការបូជាសេយ្យ
សូមពរជ័យទេវតារក្សាស្ថាន ៗ
មួយបូជាព្រះពាន់ពុទ្ធរូប
នូវព្រះស្តូបចេតិយពីបុរាណ
ទាំងអ្នកតាមហារាជវទ្ធីហាន
តាមលំអានបុរាណរាជវេណី ៗ
លុះដល់ថ្ងៃ ១៣ តិត្តីជូន
ពួកខុននាងរៀបខ្លួនគ្រប់នាទី
ចាំទទួលលោកធំចៅធានី

មើលត្រួតត្រាក្បាសត្រូវទ្រង់ ។
ពួកក្រុមពាំងលោកពាំងនាយចាងហ្វាង
ភ្នាក់ងារខាងស្តីការស្នំខាងក្នុង
ក្រុមតម្រួតនាយត្រួតព្រះដំរង្គ
លោកព្រះស្តេចស្តីការសង្ឃការី ។
អគ្គពជយមពជក្រុមមឿង
សត្រីរឿងអាជ្ញាការផែនដី
ក្រឡាហោមចក្រីទីកុង្សយ
ភ្នាក់ងារស្តីតាមទីបតុស្តម្ភ ។
ឯខុនណាងខាងក្រៅណាកដំណែង
ភ្នាក់ងារតែងគ្រប់មុខទាំងតូចធំ
សឹងព្រមព្រៀងនៅរៀងពេនថៃវធំ
តាមក្រុម ៗ ខ្ញុំពុំស្គាល់ទេលោកអើយ ។
គ្រាន់ទឹងតែងឲ្យគ្រប់ឈ្មោះអស់លោក
គិតប្រយោគទៅទៀតពុំបានឡើយ
ពេលក៏ជួនចុះយប់ព្រលប់ហើយ

ខ្ញុំក៏នឿយវិលទៅទីនិទ្រា ៗ
ពេលយប់នោះការហួងទើបដល់ថ្មី
ក្រុមមន្ត្រីសម្រាកតែរាល់គ្នា
ពុំទាន់មានរាជការនឹងពណ៌នា
ខ្ញុំនិទ្រាលក់ទៅតាមសម័យ ៗ
លុះព្រឹកឡើង ១២ ថ្ងៃអាទិត្យ
ចមបពិត្រព្រះកែវហ្វាសុឡាឡៃ
ស្តេចរៀបគ្រឿងពលីការបូជាសេយ្យ
សូមពរជ័យទេវតារក្សាស្ថាន ៗ
មួយបូជាព្រះពាន់ពុទ្ធរូប
នូវព្រះស្តូបចេតិយពីបុរាណ
ទាំងអ្នកតាមហារាជឫទ្ធិហាន
តាមលំអានបុរាណរាជវេណី ៗ
លុះដល់ថ្ងៃ ១៣ តិត្តីជួន
ពួកខុននាងរៀបខ្លួនគ្រប់នាទី
ចាំទទួលលោកធំចៅធានី

គូវៃវណើរមកពីព្រៃនគរ ៗ
លុះលោកដល់ក៏ចូលទីប្រជុំ
ពួកមន្ត្រីតូចធំគ្រប់ទិករ
សឹងទទួលគំនាប់ដោយសាទរ
ចមនគរក៏ទ្រង់ត្រេកគំនាប់ ៗ
លោកសក្តិ៣ ថែមថបកកាសា
ចែងកិច្ចាទទួលក្រសែសត្វ
ចក្រពង្សក៏ទ្រង់ឥដ់ប្រថាប់
តាមព្រះច្បាប់ស្តេចទ្រង់គង់ស្តាំដៃ ៗ
លុះសុរេចសន្ទនាវេលានោះ
គូវៃវណើរលាចុះឡើងរថរៃ
ទៅផ្ទះខាងត្បូងព្រះរាំងជ័យ
សម្រាប់ទីអាស្រ័យបាពាំងនៅ ៗ
ខ្ញុំមើលសក្តិប្រាំចាំមិនជាក់
ឃើញតែពាក់គ្រឿងសក្តិប៉ាក់ប៉ានផ្កៅ
រូបលោកតាបភាពធាត់មាត់ស្រមូវ

មើល ៗ ទៅគួរខ្លាចពុំអាចជិត ៗ
គេចមកមើលអ្នកលេងល្បែងបៀប៉ោ
ខ្លះក៏បាញ់សោហោប៉ៅស្ងិត
ខ្លះបានឈ្នះក៏ត្រេកតម្រេកចិត្ត
ខ្លះរេគិតកែកុនដោយកលកោង ៗ
ខ្លះឈ្នះប៉ោបាញ់បៀសសៀរជួ
ចាក់មួយតៅខុសមួយតួក៏ស្បើយស្បោង
បែរត្រឡប់ប្តូរប្រាក់ចាក់អាប៉ោង
ត្រូវចិនគោងអស់ប្រាក់ធ្លាក់ចង្កា ៗ
ចាប់យីគីស៊ីមួយសងដល់ដប់
ចិនប្រសប់ខ្មែរកែបញ្ញា
ទោះជាត្រូវយូរទៅគង់អបរា
បានដែកដាក់ថង់កុំសង្ស័យ ៗ
ខ្ញុំមើលគេរេគិតដល់ខ្លួនឯង
មិនគួរលុះការល្បែងឲ្យចង្រៃ
ទុកទិញបាយចំណីត្រីអាស្រ័យ

យល់ជាមានកម្រៃបានផ្អែតពោះ ៗ
ឯជាតិល្បែងលេងភ្នាល់មិនចាល់ចេះ
ឈ្នះឯណោះចាញ់ឯណោះមិនខានសោះ
ការលោកលង់គង់លាញប្រទាញឈ្មោះ
តែដល់គ្រោះគង់ក្រកម្រក្រៃ ៗ
ខ្ញុំមើលគេបានតិចគេចទៅផ្សារ
ទិញចំណីអាហារបាយអាស្រ័យ
សូរេចកិច្ចសុរិយេជ្រេមាត់ព្រៃ
បាត់សែងថ្ងៃខែខេងរៀសែង ៗ
ទៅភ្នាក់ងារនាំគ្នាតែងពេងពំ
ទាំងពេងទងឆ្វេងស្ដាំសឹងខ្វាត់ខ្វែង
អុជប្រទីបផ្កាលាភ្លើងភ្លឺទែង
ជាជួរវែងដល់ចុងផ្ទះបារាំង ៗ
លើខ្លោងទ្វារអុជជាត្រាផែនដី
មកុដច័នរង្សីព្រះពានតាំង
ស្វេត្រច្ឆ័ត្រឆ្វេងស្ដាំប្រចាំបាំង

ភ្លឺទូទាំងភពដរាំងត្រឆាឆាយ ៗ
មើលពន្លឺកគ្រឹកគ្រឹនអនេកក្រៃ
ស្ពានតែព្រែជាលជាសទកាសសាយ
បណ្តាពួកប្រុសស្រីផងទាំងឡាយ
សឹងសប្បាយនាំគ្នាមើលត្រៀបត្រា ៗ
លុះដល់ពេលហ៊ុមពេងភ្នាក់ផារហ៊ោ
កើរពេទ៍ណៃណណកដើតឈឹងឆា
ពួកអ្នកស្រុកក៏ចូលមើលត្រៀបត្រា
ណៃទទាំងមហាពជពេងកងសព្វសែ ៗ
សឹងប្របៀតជ្រៀតគ្នាដែកមិនចុះ
នរណាលុះក៏ស្ទុះទៅមុខគេ
នរណាខ្លាចមិនអាចប្របៀតទេ
ត្រូវឈរមើលក្រោយគេឃើញត្រដរ ៗ
នរណាខ្ពស់គេត្រាន់មើលស្រួលពប
នរណាទាបតោងរកដើងម៉ាត
បើស្រីណាកាន់ខ្លួនថាទួនល្អ

តែចូលទៅក្នុងបគន់អប្រិយ៍ ។
ពួកអ្នកលេងហែងដើរត្រដុះ
ជាច្នេះប្នោះឲ្យលុះការលោកិយ៍
ខ្ញុំយល់ៗ អាណិតពួកស្រី ៗ
ប្រុសអប្រិយ៍យាយីជាទីហ្មង ។
ខ្វះមានញាតិបងប្អូនជូនព្យាបាល
រក្សាការពួកពាលកុំគទ្វង
ឯណាគ្មានពូជពង្សវង្សផៅផង
ពាលហាលងឲ្យកលួនកួនដោយកាម ។
អនិច្ចានារីរូបស្រងាំ
មិនគួរមកមើលហាំឲ្យពាលតាម
ជាកូនចៅនរណាម្តេចមិនហាម
បណ្តោយតាមចិត្តកូនឲ្យខូចខ្ចោះ ។
ខ្ញុំឃើញគេឆុបារការគួរស្អប់
គេចត្រឡប់ចាកចេញពីទីនោះ
ដើរមកក្រៅមើលភ្លើងគេអុជប្រុះ

ខំដើរឆ្ពោះទៅស្តាប់ក្មេងបាកាំង ៗ
ឃើញតាហានខ្មែរយើងរូបក្មេងៗ
ឈរដំកង់តាំងលេងនៅមុខវាំង
មាននាយត្រួតបន្លឺសព្ទដូចស័ង្ខ
ស្គរមួយតាំងក្រាំងៗ តាមបង្អាក់ ៗ
ត្រែតូចៗ ដូចក្ងយខ្ទះវៀនជុំ
ត្រែធំៗ រំឆ្ងាយដូចគេផ្ទាក់
កាន់សៀវភៅកាល់ដៃផ្ទុំមើលថ្នាក់
ខិតៗ ដាក់តាមបង្អាក់ព្រមៗគ្នា ៗ
សែនពិរោះសព្ទត្រែសេលាន់កង
ចប់ចុះម្តងឡើងថ្មីបំភ្លៃឃ្លា
មេឡើងហែបកូនអែបប្រសព្វគ្នា
ស្តាប់ហាក់ជាក្មេងកុម្ពណ្ណលាន់ពុសាយ ៗ
ពួកបាកាំងរៀបតាំងលៀងស៊ុក
សព្វគ្រយាអាហារគ្រឿងពីនាយ
បោយបំរើតាញផ្ចិតជាប់កាយ

កំសាន្តកាយដោយភ្លេងលេងប្រគំ ៗ
លុះម៉ោងជប់ជួនយប់រួចការលៀង
ពួកបាពាំងព្រមព្រៀងទាំងតូចធំ
នាំគ្នាដើរមើលការទីប្រជុំ
សែនភិរម្យលោះលាយសប្បាយក្រៃ ៗ
ពួកអ្នកលេងដើរទិញបារីស្លា
ខ្លះចូលស្រាក៏ទិញស្រាអាស្រ័យ
ពួកអ្នកលក់ឃើញមនុស្សទិញច្រើនក្រៃ
តម្លើងថ្លៃយកកម្រៃលើសប្រក្រតី ៗ
លុះព្រឹកឡើងថ្ងៃជ្រេព្រះទិនករ
ចមកូធរចេញគង់ព្រះពេនថ្មី
ព្រមវង្សានុវង្សក្រុមក្សត្រីយ
ទាំងមន្ត្រីតូចធំជុំត្រៀបត្រា ៗ
មានតម្រាស់ត្រាស់ឲ្យចាត់ចែងទី
រាជពិធីចំរើនព្រះជន្មា
មន្តព្រះសង្ឃសូត្រមន្តតាមវេលា
ចំនួនគ្រប់ជន្មាចិតសិបបុាយ ៗ

លោកមង្គលទេពាចារ្យធំបំផុត
ចំណែកខាងធម្មយុត្តិសង្ឃទាំងឡាយ
លោកមហាវិមលកបកិប្រាយ
ជាពួកខាងមហានិកាយអធិបតី ៗ
ព្រមព្រះគ្រូកជាគណៈក្រៅ
សឹងផ្ដុំនៅនាចុងព្រះពាងថ្មី
ថ្វាយពុទ្ធមន្តចំរើនពជសួស្ដី
មង្គលកិច្ចឱ្យស៊ីសុវត្ថិ ៗ
ចក្រពង្សទ្រង់តាំងលោកពុទ្ធវង្ស
ប្រោសឲ្យគង់ក្នុងដែននគរវត្ត
ខាងអាចារ្យបាសកបេះបរិយត្តិ
គឺអាចារ្យកុមគាត់បេះសាស្ត្រា ៗ
ប្រោសប្រទានគ្រឿងយសអាចារ្យកុម
ឡើងជាធំទីសទ្ធម្មមេធា
ជាចាងហ្វាងខាងពួកត្រៃវិជ្ជា
ប្រចាំនានគរវត្តព្រាកដហោង ៗ

កំសាន្តកាយដោយក្មេងលេងប្រគំ ។
លុះម៉ោងដប់ដួនយប់រួចការលៀង
ពួកបារាំងព្រមព្រៀងទាំងតូចធំ
នាំគ្នាដើរមើលការទីប្រជុំ
សែនកិរម្យលោះលាយសប្បាយក្រៃ ។
ពួកអ្នកលេងដើរទិញបារីស្លា
ខ្លះបូលស្រាក៏ទិញស្រាអាស្រ័យ
ពួកអ្នកលក់ឃើញមនុស្សទិញច្រើនក្រៃ
តម្លើងថ្លៃយកកម្រៃលើសប្រក្រតី ។
លុះព្រឹកឡើងថ្ងៃជ្រេព្រះទិនករ
បមកូធរចេញគង់ព្រះពេនថ្មី
ព្រមវង្សានុវង្សក្រុមកុង្សីយ
ទាំងមន្ត្រីតូចធំជុំត្រៀបត្រា ។
មានតម្រាស់ត្រាស់ឲ្យចាត់ចែងទី
រាជពិធីចំរើនព្រះជន្មា
មន្តព្រះសង្ឃសូត្រមន្តតាមវេលា
ចំនួនគ្រប់ដ្នាចិតសិបបាយ ។

លោកមង្គលទេពាចារ្យធំបំផុត
បំណែកខាងធម្មយុត្តិសង្ឃទាំងឡាយ
លោកមហាវិមលកបកិប្រាយ
ជាពួកខាងមហានិកាយអធិបតី ។
ព្រមព្រះគ្រូភជាគណៈក្រៅ
សឹងផ្ដុំនៅនាចុងព្រះពេងថ្មី
ថ្វាយពុទ្ធមន្តចំរើនពជសួស្ដី
មង្គលកិច្ចឱ្យសុីសុវត្តិ ។
បក្រពង្សទ្រង់តាំងលោកពុទ្ធវង្ស
ប្រោសឲ្យគង់ក្នុងដែនទគវត្ត
ខាងអាចារ្យបាសកបេះបរិយត្តិ
គឺអាចារ្យក៊ុមគាត់បេះសាស្ត្រា ។
ប្រោសប្រទានគ្រឿងយសអាចារ្យក៊ុម
ឡើងជាធំទីសទ្ធម្មមេធា
ជាចាងហ្វាងខាងពួកត្រៃវិជ្ជា
ប្រចាំនានគរវត្តប្រាកដហោង ។

លុះពេលយប់អុជកាំជ្រួចរន្ទា
ភ្លឺគោហៀនូវគ្រឿងដទៃផង
ពួកល្ខោនក៏រាំដូចសព្វដង
អស់មនុស្សផងមកមើលដូចសព្វគ្រា ។
លុះដល់ថ្ងៃដប់ប្រាំវេលាព្រឹក
មានពិធីដឹកទឹកព្រះសច្ចា
ប្រជុំពួកមន្ត្រីសេវកា
ព្រាហ្មណ៍ហោរាជាធំក្នុងពិធី ។
តាំងនៅនាព្រះភ័ក្ត្រនៃព្រះពាន់
ព្រះបរខ័ណ្ឌក៏ទ្រង់យាងចរលី
នាំព្រះវង្សក្សត្រិយ៍ក្រុមយោធី
ឡើងកាន់ទីប្រាង្គធំប្រជុំការ ។
លោកសក្តិប្រាំសក្តិបីព្រៃនគរ
ក៏ស្មោះសរបរតាមព្រះករនាថ
តាំងនាមុឺនក្នុងក្រៅគ្រប់មុខងារ
ទទួលការទានទឹកប្រណិធាន ។

លុះជុំព្រមព្រាហ្មណ៍ហោរសូត្រពិធី
ប្រណិធានតាមទីពីបុរាណ
កូរអាវុធចុះជាទិព្វញ្ញាណ
ស្រេចទើបកជទានក្រុមនានា ៗ
ទៅហ្វាយខែត្រសៀមកបព្រះដំបង
ជានាយកងក្រុមក្រៅព្រះរដ្ឋា
លោកកុន្សីយអធិបតីក្នុងសីមា
ទទួលទឹកព្រះសច្ចាការកិរ្យ ៗ
លុះស្រេចពិធីទឹកសម្បថ
បក្រពត្រក៏ទ្រង់គង់ប្រជុំ
គូវែរណេររ៉េស៊ីដងត៍កំពង់ជំ
គាល់ប្រជុំជំនុំតាមកិច្ចា ៗ
ទ្រង់ឲ្យហូតនាទីអាជ្ញាហ្លួង
នាយក្រសួងសក្តិបីកជអាជ្ញា
ទាំងលោកជំកុម្មីសែរតែស្រុក
ឲ្យផ្តាសវិលគាកក្តីពេញហោង ៗ

លុះពេលយប់អុជកាំជ្រួចរន្ទា
ភ្លឺគោហៀនូវគ្រឿងដទៃផង
ពួកល្ខោនក៏រាំដូចសព្វដង
អស់មនុស្សផងមកមើលដូចសព្វគ្រា ។
លុះដល់ថ្ងៃដប់ប្រាំវេលាព្រឹក
មានពិធីផឹកទឹកព្រះសច្ចា
ប្រជុំពួកមន្ត្រីសេវកា
ព្រាហ្មណ៍ហោរាជាធំក្នុងពិធី ។
តាំងនៅនាព្រះភ័ក្ត្រនៃព្រះពាន់
ព្រះបរខ័ណ្ឌក៏ទ្រង់យាងចរលី
នាំព្រះវង្សក្សត្រីយ៍ក្រុមយោធី
ឡើងកាន់ទីប្រាង្គធំប្រជុំការ ។
លោកសក្តិប្រាំសក្តិបីព្រៃនគរ
ក៏ស្មោះសរបរតាមព្រះភវនាថ
ទាំងនាម៉ឺនក្នុងក្រៅគ្រប់មុខងារ
ទទួលការទានទឹកប្រណិធាន ។

លុះជុំព្រមព្រាហ្មណ៍ហោរសូត្រពិធី
ប្រណិធានតាមទីពីបុរាណ
ភូរអាវុធចុះជាទិព្វញាណ
សូរេចទើបរាជទានក្រុមនានា ៗ
ចៅហ្វាយខែត្រសៀមរាបព្រះដំបង
ជានាយកងក្រុមក្រៅព្រះរដ្ឋ
លោកកុង្ស៊ីយអធិបតីក្នុងសីមា
ទទួលទឹកព្រះសច្ចាការកិរិយ ៗ
លុះសូរេចពិធីទឹកសម្បថ
បក្រពត្រក៏ទ្រង់គង់ប្រជុំ
គូវែរណើររ៉េស៊ីដងត៍កំពង់ជំ
គាល់ប្រជុំជំនុំតាមកិច្ចា ៗ
ទ្រង់ឲ្យហូតនាទីអាជ្ញាហ្លួង
នាយក្រសួងសក្តិបីរាជអាជ្ញា
ទាំងលោកជំកុម្មីសែរតស្យក
ឲ្យផ្លាស់វិលភារក្នុំពេញហោង ៗ

យកលោកធំរើស៊ីដង់ត៍កំពង់ស្វាយ
ឡើងជានាយកុម្មីសែរព្រះដំបង
មួយពជការសុខទុក្ខអស់ពស្រ្តផង
ទៅហ្វាយខែត្រព្រះដំបងជាឥស្សរ ៗ
លុះប្រជុំរួចស្រេចស្តេចវន្ទីយ៍
អញ្ជលីលារូបព្រះសាស្តា
ទ្រង់យាងបាទចេញតាមទ្វារបច្ឆិមា
ព្រមព្រះវង្សពង្សាហែចេញឋាន ៗ
ពួកអ្នកថតចាំថតព្រះរូបទ្រង់
ឲ្យជាប់ជុំទាំងវង្សព្រះប្រាង្គស្ថាន
ខ្ញុំឃើញគេពេញកោតគេចំណាន
ថតយកបានព្រះឆាយកាយកូធរ ៗ
លុះយាងដល់កនបាលមុខព្រះលាន
ពួកទាហានអាវុធសលុតឈរ
ស្តេចឡើងគង់ព្រះសលៀងពជបវរ
ពួកអ្នកសែងហែចរចូលវាំងថ្មី ៗ

លុះដល់ស្រេចស្តេចចូលព្រះរោងធំ
ថ្វាយបង្គំព្រះសង្ឃទាំងចាស់ខ្ចី
អង្គាសភត្តភេសជ្ជៈថ្វាយចំណី
ក្រុមសង្ឃការីចាត់ការបង្ហាន់សង្ឃ ៗ
ព្រះសង្ឃសូត្រទទួលពជភត្ត
តាមកំណត់ពេលនោះថ្ងៃទៀបត្រង់
សូរេចកិច្ចសង្ឃលាព្រះចក្រពង្ស
ស្តេចក៏ទ្រង់ចូលកាន់ព្រះពន្លា ៗ
លុះដល់ពេលសូរិយេជ្រេស្រទន់
ឲ្យនិមន្តព្រះសង្ឃសង្គាយនា
ចំនួនអង្គមួយរយដោយគណនា
លោកទេសនាត្រៃបីតាមព្រេងព្រឹទ្ធ ៗ
ទីឱ បាលីវិន័យធរវត្តតាមិម
អានទួគឹអាចារ្យគិមវត្តពិកិត
ទ៏កស្របព្រះគ្រូវត្តបូរពិត
ចៅគណសង្ឃស្ថិតស្រុកសៀមរាប ៗ

រកលោកធំរ៉េស៊ីដង់ត៍កំពង់ស្វាយ
ឡើងជានាយកុម្មីសែរព្រះដំបង
មួយរាជការសុខទុក្ខអស់រាស្ត្រផង
ទៅហ្វាយខេត្រព្រះដំបងជាឥស្សរ ៗ
លុះប្រជុំរួចស្រេចស្តេចវន្ទីយ៍
អញ្ជាលីលារូបព្រះសាស្តា
ទ្រង់យានបាទចេញតាមទ្វារបច្ឆិមា
ព្រមព្រះវង្សពង្សាហែចេញថ្កាន ៗ
ពួកអ្នកថតចាំថតព្រះរូបទ្រង់
ឲ្យជាប់ជុំទាំងវង្សព្រះប្រាង្គស្ថាន
ខ្ញុំឃើញគេពេញគោកគេចំណាន
ថតយកបានព្រះឆាយកាយកូធរ ៗ
លុះយាងដល់ពនហាលមុខព្រះលាន
ពួកទាហានអាវុធសលុតឈរ
ស្តេចឡើងគង់ព្រះសលៀងរាជបវរ
ពួកអ្នកសែនហែចរចូលវាំងថ្មី ៗ

លុះដល់ស្រេចស្តេចចូលព្រះរោងធំ
ថ្វាយបង្គំព្រះសង្ឃទាំងចាស់ខ្ចី
អង្គាសកត្តកេសដ្ឋៈបាយចំណី
ក្រុមសង្ឃការីចាត់ការបង្ហាន់សង្ឃ ៗ
ព្រះសង្ឃសូត្រទទួលពជកត្ត
តាមកំណត់ពេលនោះថ្ងៃទៀបត្រង់
ស្រេចកិច្ចសង្ឃលាព្រះចក្រពង្ស
ស្តេចក៏ទ្រង់ចូលកាន់ព្រះពន្លា ៗ
លុះដល់ពេលសូរិយេជ្រេស្រទន់
ឲ្យនិមន្តព្រះសង្ឃសង្គាយនា
ចំនួនអង្គមួយរយដោយគណនា
លោកទេសនាត្រៃបីតាមព្រេងព្រឹទ្ធ ៗ
ទី១ បាលីវិន័យធរវត្តតាមិម
អានន្ទគឺភេចាវ្យគិមវត្តពិកិត
ទីកស្សបព្រះគ្រូវត្តបូរពិត
ទៅគណសង្ឃស្ថិតស្រុកសៀមរាប ៗ

សង្គាយនាបឋមតាមវេណី
ក្នុងគម្ពីរបិដកតាមសភាព
លុះចប់ចុះពេលថ្ងៃស្រទន់ទាប
សង្ឃបានលាភក៏វិលវត្តអាត្មា ៗ
ពេលយប់នោះមានការលេងអាប៉េ
ក្បួនយីកេកំឡុកបកភាសា
ពួកអ្នកស្រុកក៏មកមើលគ្រៀបគ្រា
សែនមហាសប្បាយលោះណាយក្រៃ ៗ
លុះដល់ថ្ងៃមួយពេចរួចពិធី
ឲ្យចាត់ហែព្រះគម្ពីរបិដកថ្ងៃ
ចូលតម្កល់តាំងទុកនៅហោត្រៃ
សម្រាប់នៃកុលបុត្រអ្នកសិក្សា
ថ្ងៃពីរពេចឮថាបក្រពង្ស
ក្រសាលស្រះស្រង់ទិសបច្ឆិមា
ឯខ្ញុំបាទក៏នាំកឿនយាត្រា
ទៅមើលក្រុងភាពនគរធំ ៗ

លុះដើរដល់ទូគេមភ្នំបាខែង
ព្រៃត្រសុំបាំងសែងសែនកិរម្យ
ដើងគិរីមានសិង្ហតាំងត៏រមុម
ឈរចំអែបែរចំទិសបូព៌ា
សិង្ហបាសាណបុពណលោកសំអាង
មើលដូចយ៉ាងសិង្ហសត្វពជសីហា
ធាត់ក្រអួនខ្លួនក្រអាញក្រាញដូចខ្លា
ចំអេងស្មាឈរអើតចំទើតដើង ៗ
ខ្ញុំយល់សិង្ហឈរនឹងពុំកម្រើក
ចង់តែលើកយកមកទុកស្រុកយើង
តែធំហួសផុតការលើកមិនឡើង
ទឹងបបើងលើកយកពុំរួចឡើយ ៗ
អនិច្ចាសិង្ហអើយសិង្ហបាសាណ
ខ្ញុំយកទៅពុំបានណាសិង្ហអើយ
ឯងនៅចុះឲ្យសុខកុំទុក្ខឡើយ
សិង្ហហើយមកនៅក្នុងព្រៃស្ងាត់ ៗ

បើសិង្ហឯងរស់ពិតជីវិតមាន
គួរជានៅស្មសានសន្តានសត្វ
ស្វែងអាហារលៀងជីពពុំសូវខាត់
នេះមកបាត់វិញ្ញាណមានតែប្រាណ ។
នឹងដើរទៅទីណាក៏ពុំកើត
នៅតែឈរចំអើតប្រចាំដាន
ស្តាយអើយស្តាយរូបសិង្ហលោកបុកណា
បោលក្នុងស្ថានស្មសានអនាថា ។
ខ្ញុំសម្តេចរូបសិង្ហប្រឹងឡើងភ្នំ
ថ្មតូចធំជិតជុំជាន់រអា
ខ្ពស់ត្រឈឹងខំប្រឹងឡើងប្រាប់
លុះដល់នាកំពូលគិរីឋាន ។
លើបាខែងលោកតែងជាសថ្ងូប
មានរួតរូបប្រាំជាន់ជាដាន ៗ
ខាងបូព៌ាមានប្រាង្គតាំងបួនស្ថាន
វិចិត្រជាយបាសាណឥដ្ឋសិលា ។

ខាងមុខប្រាង្គមានឡាយព្រះបាទព្រះ
វាលស្រឡះពុំមានគ្រឹះលេខា
ដាប់ទម្លុះផ្លុះចុះក្នុងសីលា
ខាងលើលោកតាំងជាវិហារបាំង ៗ
តែវិហារនោះឯងលោកតែងថ្មី
ធ្វើដោយឈើដោយបុស្សីប្រក់ស្បូវក្លាំង
ពីបុរាណមានតែរណ្ដៅតាំង
ថ្មរឹងតាំងនៅបណ្ដូលគោលសិលា ៗ
ពុទ្ធបាទខ្នាតជ្រៅជំរៅបាត
ប្លាយហាត់ខ្នាតបណ្ដោយបួនហត្ថ
ទទឹងសោតពីរហត្ថជាមាត្រា
ក្នុងបាទាលាយលក្ខណ៍កងចក្រជុំ ៗ
លោកវិចិត្របិទមាសវិលាសលឿង
មើលរុងរឿងគួរយើងឡើងបង្គំ
សព្វថ្ងៃមានលោកយួនគេជាធំ
នៅថែទាំពិតក្ដីរក្សាស្ថាន ៗ

ខ្ញុំយល់ព្រះពុទ្ធបាទអនាថបិត្ត
គិតដល់អង្គអគ្គនិដ្ឋព្រះទ្រង់ញាណ
កាលព្រះអង្គស្តេចទឹងចូលនិព្វាន
ព្រះទ័យមានមេត្តាដល់នរជាតិ ។
សត្វឯក្រោយពុំបានយល់សាស្តា
បានទាន់តែសាសនាបរមនាថ
ទើបប្រតិស្ឋានព្រះពុទ្ធបាទ
និងឆកទឲ្យប្រោសអស់សត្វផង ។
ឆព្រះគុណបានបុណ្យលន់វិសេស
ទ្រង់កំចាត់កិលេសជាគ្រឿងហ្មង
បាននិព្វាននៅមានព្រះទ័យចង
តម្កល់បាទតាងស្នងព្រះពុទ្ធអង្គ ។
ទុកឲ្យសត្វឯក្រោយបានបូជា
ជាផ្លូវទៅសួគ៌ាឋានទេពទ្រង់
សាងកុសលទាល់បានកាត់កគបង់
មិនយូរលង់គន់បានឋានសុខា ។

វេលានេះខ្ញុំមកដោយការខាត់
ពុំមានអ្វីប្រតិបត្តិចាត់បូជា
មានតែដៃទាំងដប់ខ្ញុំវន្ទា
ចិត្តវាចាបូជាក្នុងគ្រានេះ ៗ
ឱព្រះបាទនេះជាព្រះជាន់ឬ
ឬមួយគឺគេសាកទុកទេអេះ
ក្នុងតម្រាពុំមានតាំងភ្នំនេះ
បើតាមរិះយ៉ាងសំណាកគេសាកថ្មី ៗ
បញ្ចាបាទទាំងប្រាំសឹងមានជាន
ឈ្មោះគេមានគ្រប់ស្ថានទាំងប្រាំទី
ភ្នំបាខែងពុំមានក្នុងព្រះគម្ពីរ
ជាក់ជាទីកើតក្រោយដោយនិយាយ ៗ
ខ្ញុំវន្ទាព្រះបាទស្រេចលាចុះ
តម្រង់ឆ្ពោះកាត់ទៅមើលនគរធំ
ផ្លូវធ្លាថ្នល់សឹងឈើម្លប់ត្រសុំ ៗ
គេរំលំកាត់ត្រង់នគរ

លុះដើរដល់ខ្លោងទ្វារនគរធំ
សុទ្ធសឹងជុំថ្មជិតប្រកិតគ្នា
កំពូលខ្ពស់សិនសេសដោយគណនា
ចម្លាក់ជារូបទេពប្រណម្យដៃ ៗ
កំពូលលើឈើដុះទម្លុះចាក់
ថ្មរុះជ្រុះធ្លាក់ខ្ចាយពយដោយព្រៃ
នៅតែពងដូចយ៉ាងព្រះប្រាង្គជ័យ
ចូលអាស្រ័យចុះមនុស្សជាងរយនាក់ ៗ
ផ្ទៃកំពែងតែងដោយថ្មក្រៀមក្រាស់
បូកដីជាសពាសប៉ះឡើងថ្នាក់ ៗ
កម្រាស់ក្រាស់ប្រមាណបីព្យាមជាក់
ធំអនគ្ឃវែងអនេកលើសគណនា ៗ
ក្រៅនគរតែងឃូកសិណសាយ
មើលវែងឆ្ងាយឧបអមនគរ
តែឥឡូវស្ងាតជិតដោយព្រឹក្សា
បិទគន្លាកើតជាត្រឹបតាប់តាន់

មើលខ្លោងទ្វារពណ៌នាពុំអស់ក្បួន
ពេលក៏ដួនទៀបទោរព្រះសុរិយ័ន
ខំកាត់ចូលបូរីដោយបន្ទាន់
ដល់ប្រាសាទបាយ័នពជកិរម្យ ៗ
ប្រាង្គបាយ័នលោកសាងជាប្រាង្គមូល
មានកំពូលប្រាង្គចេញជាបួនមុម
ក្នុងកំពូលមួយ ៗ ឆ្លាក់រូបព្រហ្ម
បួន ៗ ជុំគ្រប់ប្រាង្គប្រុងប្រាងក្រៃ ៗ
ឯរោងទងជុំវិញជ្រុងកែងកាត់
ទ្វារលោកចាត់កាត់មួយទ្វារមួយនៃ
ក្នុងឡប់ឡៃបមុខទៅទីទៃ
ចតុរស្រស្មើផ្ទៃបីជាន់សាយ ៗ
ឱប្រាង្គនេះមើលទៅសម្បើមលន់
ខ្ញុំគន់ ៗ គិតទៅគួរតែស្តាយ
ប្រាង្គនេះតើជាក់ឬពីព្រេងនាយ
តាមបរិយាយគឺជាក់ភាពហោនី ៗ

គឺកាលដើមកាន់សាសនាព្រាហ្មណ៍
ប្រព្រឹត្តតាមតម្រាព្រះសូលី
យកយោនីឧមាភោគវតី
ជាសិរីសួស្តីតាំងបូជា ។
គេយល់ថាមនុស្សយើងលើធរណី
កើតចេញពីយោនីនាងឧមា
នាងជាម្តាយមានគុណទាំងលោកា
ទើបនាំគ្នាសាងជាកំណើតហោង ។
បើមានការមង្គលចំរើនបុត្រ
ព្រាហ្មណ៍យកទឹកស្រោចភាពបង្ហូរត្រង
មកប្រសិទ្ធិស្រោចអស់មហាជនផង
បំបាត់ក្តីសៅហ្មងចាកឥន្ទ្រិយ៍ ។
ភាសាព្រាហ្មណ៍គេកាន់តម្រាសៃយ
ទើបកែខែបម្លែងរូបយោនី
សាងប្រាង្គនេះតាំងជាមន្ទីរទី
លោកសញ្ញីឲ្យហៅថាបាយ័ន ។
ឯសព្ទ "បា" នោះថាមូតមួយ ៗ

តាមតម្រួយសព្ទ "បា" គឺមួយខណ្ឌ
យ័ន សព្ទនេះពុំមែនជាលេខយន្ត
កុំប្រកាន់យន្តលេខតាមភាសិត ។
សព្ទ "យ័ន" នេះគឺជាភាសាព្រាហ្មណ៍
មានក្នុងក្បួនសព្ទនាមប្លែងសំស្រ្កឹត
ខ្ញុំមើល ៗ បាយ័នក៏តូចចិត្ត
ទឹកអាណិតដល់ក្សត្រពីបុរាណ ។
លោកមានបុណ្យកសាងប្រាង្គបាយ័ន
ទុកក្នុងខណ្ឌទិវេសន៍នៃក្សត្រក្សាន្ត
មានទេសកាលក៏ឡើងប្រតិស្ឋាន
ស្រោចស្រប់ប្រាណដោយទឹកនាងឧមា ។
សែនរុងរឿងថ្កើងបុណ្យថ្កើងកេរ្តិ៍ឈ្មោះ
កិត្តិសព្ទឮសុសសព្វគ រា
បរទេសពជកោតខ្លាចឡើងវន្ទា
ពស្រ្តប្រជាសឹងក្សាន្តសម្រាន្តកាយ ។
ឥឡូវនេះទិវេសន៍ទៅជាព្រៃ

តាំងប្រាង្គជ័យក៏ដល់ក្តីអន្តរាយ
ឃើញតែស្នាដៃធ្វើបែបឡែបខាយ
ស្តាយអើយស្តាយមិនគួរមកម្លេះណា ៗ
ទីខាងជើងមានវត្តលោកសង្ឃនៅ
ព្រះនាមហៅព្រះង៉ោកលោកលេខា
ឱព្រះង៉ោក ៗ មែនឬយ៉ាងណា
ឮគេថាយល់ជាអស្ចារ្យក្រៃ ៗ
ខ្ញុំទៅមើលពុំឃើញព្រះលោកង៉ោក
គិតប្រយោគយល់ថាព្រះម្ចាស់ថ្លៃ
រូបព្រះធំលន់លើសព្រះដទៃ
ឯងរំពៃមើលដុបដូចង៉ោកមក ៗ
វត្តមួយខាងបស្ចិមគ្មានលោកសង្ឃ
កុដិវិហារដូចបង់គ្មានទីជ្រក
វត្តនោះឯងគេហៅវត្តគោកធ្លក
តនោះមកវត្តត្បូងបោលដូចគ្នា ៗ
វត្តនោះហៅព្រះឥន្ទទេពកោសី

អង្គព្រះដីវក៏ធំសមរូបា
កុដិវិហារបាំងព្រះគ្មានឡើយណា
អនិច្ចាមើលទៅសម្ដេចក្រៃ ៗ
ឱអង្គព្រះឥន្ទទេពកោសីអើយ
មិនគួរឡើយមកនៅកណ្ដាលព្រៃ
អាប់ពសីដោយសែងហែងដោយថ្ងៃ
ទីអាស្រ័យពុំមានក្សាន្តព្រះកាយ ៗ
បើព្រះអង្គទៅគង់ស្រុកខ្ញុំក៏
ខ្ញុំនឹងសាងសាលាវិហារថ្វាយ
តាំងគ្រឿងតុគ្រឿងតាំងឲ្យឆើតឆាយ
ដូចជាព្រះទាំងឡាយស្រុកព្រះដំបង ៗ
គ្រាន់និមន្តជូនលើកទៅពុំបាន
ព្រោះធំហួសប្រមាណជូនកន្លង
បើអង្គតូចទៅក៏នឹងក៏បាន
ដាក់ដឹកជូនមកស្រុកទុកបូជា ៗ
ឱលោកណាសទ្ធាសាងព្រះនេះ

ម្តេចមិនរិះត្រិះមើលដោយបញ្ញា
កាលស្រុកដីមិនផុតក្តីអនិច្ចា
មកគិតថានិច្ចំតាំងទៀងទាត់ ៗ
កាលប្រទេសរុងរឿងធ្វើតាមចិត្ត
ដល់ប្រទេសវិបរិតកើតវិបត្តិ
ព្រះដីវ៍ធំនឹងរំកិលក៏កើតខាត់
តោងចាំកាត់ចិត្តបោលទុកប្ចេះណា ៗ
បើយ៉ាងព្រះតូច ៗ ល្មមយករួច
តែដល់ស្រុកខាត់ខូចដូចម្តេចម្តា
ចង់រំលៀកក៏បានដូចចិត្តា
ចុះតម្រាធំខូចតូចមិនខាត់ ៗ
ដូចពស្ត្រទាសតាំងឡើងជានាហ្មឺន
ប្រព្រឹត្តគឹនហួសការពជបញ្ញត្តិ
នឹងដកចេញចាកទីក៏មិនខាត់
តែមហាក្សត្រវិបត្តិដកពុំបាន ៗ
តោងចាំនៅទៅតាមយថាកម្ម

ទុក្ខក៏ទ្រាំទោសក៏ទ្រាំទម្រាំក្សាន្ត
ដូចព្រះអង្គឥន្ទ្រទេពជាបែបមាន
ក្សាន្តពុំបានព្រោះប្រាណធំលើសគេ ។
អនិច្ចាសាសនាព្រះជិនវង្ស
ពុំស្ថិតស្ថេរបេរលង់ក្នុងនគរ
ជាបុណ្យបាបអ្វីពីបុព្វ
បានជាប្រែបូីរព្រៃដូច្នេះ ។
ស្រុកនេះសូន្យតើសូន្យពីរាជ្យណា
ពង្សាវតារតម្រាឯណាអេះ
នឹងបានមើលឲ្យដឹងរាជ្យនោះនេះ
ខ្ញុំនឹងត្រិះឲ្យត្រូវតាមរបាក្សត្រ ។
ខ្ញុំគន់មើលវត្តបីស្រេចបរបើរ
ទៅមើលពជមន្ទីរចក្រវត្តិ
នៅខាងជើងព្រះអោកលោកបែងចាត់
ខឿនបង្ហាត់ខ្វាត់ខ្វែងវែងវឹង ។
ប្រាង្គប្រាសាទបែកបាក់ធ្លាក់ខ្ទេចខ្ទី

នៅតែទីគ្រឹះក្រោមកាត់ទទឹង
មុខប្រសាទស្ដានពបភាពជាបឹង
ជើងជណ្ដើរដើរមានសិង្ហឈរប្រឹងប្រែង ៗ
ឯផ្ទៃផ្តែរឆ្លាក់រូបរឿងក្បួនខេន
ជិះគជេន្ទ្រហែស្នួជាជួរវែង
ខាងជ្រុង ៗ រូបគ្រុឌឈរចំទែង
ខ្លះសម្ដែងចាប់រាសុក្រីក្រាយ ៗ
មុខព្រះពភនមានប្រាង្គជាកាត់ ៗ
ហៅប្រាសាទសួព្រ័ត្រខ្ពស់ត្រសាយ
ខ្ញុំយល់ ៗ នឹកកោតគេអម្បាយ
ប្រាង្គខ្ពស់ធ្លាយចង់ព្រ័ត្រហ៊ានសួបាន ៗ
ទីខាងក្រោយប្រាសាទហៅបាពួន
មើលក្បាច់ក្បួនឡប់ឡែជាជានៗ
ធុបាពួនទួននាងក្នុងវាំងស្ដាន
ចូលកំសាន្តលេងពួនបន្ទែងអង្គ ៗ
ទីខាងជើងខ្លោងទ្វារមានគ្រឹះគ្រែ
ជាថ្នាក់ហែសឹងរតួហួតហៀនហង្ស

លើមន្ទីរសាងរូបចក្រពង្ស
ស្ដេចគំលង់គង់នៅប្រចាំទី ។
ខ្ញុំយល់រូបព្រះបាទសន្ធចក្រ
គេសាកដាក់ជាឡាក់រាជធានី
កើតសម្ដេទវេទនាសល់សែនទ្វី
មិនគួរទើមកកើតវិបត្តិច្នេះ ។
ឮតម្រាបរម្បរាពីបុរាណ
ជាព្រះចមក្សត្រក្សាន្តនគរនេះ
ប្រហារនាគឈាមនាគផ្សព្វផ្សាយឆេះ
ត្រូវព្រះកាយកើតប្រែះប្រែជាឃ្មន់ ។
មើលពុំជាវេទនាពន់ប្រមាណ
ឥសីសានមកប្រោះចក្រពង្ស
ស្ដេចពុំជឿតាមពាក្យឥសីសង្ឃ
ទើបព្រះអង្គបង់ការអសារកាយ ។
ឥសីខឹងផ្ដាសារាជនិវេសន៍
ទៅប្រទេសក៏លុះក្ដីអន្តរាយ

បានជាទីស្រុកនេះកើតខ្ចាត់ខ្ចាយ
ដោយបរិយាយដៅ ៗ ពុំពិស្ដារ ៗ
ខ្ញុំត្រិះ ៗ នឹកគិះស្ដេចគំលង់
ព្រះទ័យទ្រង់មានះអហង្ការ
កើតហេតុអ៊ូទឹងនាគទើបប្រហារ
ឲ្យខូចស្រុកអសារស្នាដៃខ្លួន ៗ
គួរឬក្រែងនគរសេប្រទេសធំ
ប៉មកំពែងជិតជុំដ៏មាំមួន
សត្រូវណាទឹងអាចចូលមកក្នុង
តែគិតទៅចុះក្បួនព្រះត្រៃលក្ខណ៍ ៗ
សព្វសង្ខារមិនថាតាំងស្រុកដី
ទូបូរីសាយសព្វគ្រប់ដំណាក់
ទុកជាបេះយ៉ាងណាក៏គង់ធ្លាក់
អញ្ជើញអ្នកមើលស្ដាប់ចាប់អារម្មណ៍ ៗ
នគរធំបរមបុរាណរាជ្យ
មើលគួរខ្លាចសឹងព្រៃស្រោងស្រាងជុំ

មានអ្នកស្រុកតាំងនៅជាជុំៗ
រកស៊ីតាមនិគមអ្នកជនបទ ។
រយៈផ្លូវទៅដល់នគរធំ
ដោយនិយមវាស់ពីនគរវត្ត
ប្រមាណបានកៅសិបសិនប្រាកដ
ចូរកំណត់កត់ចុះលោករាល់គ្នា ។
ក្រែងបានទៅទឹងឆាយដឹងទិសទី
រាជធានីបុរាណទិសឧត្តរា
តែឥឡូវបារាំងគេកាប់ឆ្ការ
ទំនងជាយូរទៅគង់សប្បាយ ។
ខ្ញុំដើរគន់ដើរកត់នគរធំ
ពុំបានជុំនគរទេលោកាយ
ពេលក៏ជួនសុរិយោជ្រេព្រះឆាយ
ក៏រៀបកាយវិលមកសៀមរាបវិញ ។
លោកចៅហ្វាយលោកធំលោកសក្តិបី
សូរេចការចក្រីក្រុងភ្នំពេញ

បង្គំលាវិលព្រះដំបងវិញ
ខ្ញុំក៏អស់ក្ដីម្នេញការលោកីយ៍ ៗ
ដល់មកស្រុកសាន្ដសុខឥតទុក្ខា
ដោយអំណាចចក្រាគ្របកេសី
ទាំងគុណកែវរតនត្រៃថ្លៃទាំងបី
ជួយចំរើនរាសីឥតហ្មងសៅ ៗ

រឿងនិរាសប្រកាសតែប៉ុណ្ណេះ

សូមទុកស្មេះប្រារព្ធបញ្ឈប់នៅ
គ្រាន់នឹងតែងតអង្គព្រះបមហៅ
កាលស្ដេចនៅពុំទាន់វិលភ្នំពេញ ៗ
ខ្ញុំលាហើយពុំដឹងក្រោយយ៉ាងណា
រាជកិច្ចាពុំទាន់ប្រកាសចេញ
ហេតុដូច្នោះទុកឲ្យប្រាជ្ញភ្នំពេញ
គេតែងចេញតរឿងព្រះចក្រី ៗ
ខ្ញុំឥន្ទាចារ្យចែងតែងពុំបាន
ព្រោះគ្មានជានលំអានយោគសេចក្ដី

ហេតុនោះសូមមេត្តាប្រោសប្រណី
ខ្ញុំបញ្ចប់សេចក្តីតែប៉ុណ្ណេះ ។
    សូមទោសលោកមេធីកវីជាតិ
កុំឧបវាទពាក្យកាព្យខ្ញុំតែងនេះ
សូមតម្រូវឲ្យត្រូវតាមលោកបេះ
បើមិនផេះកុំបើកលើកចូលចេញ ។
កុំប្រមាទពាក្យកាព្យថាតែងងាយ
យារមុខតាមនិយាយដាក់បំពេញ
បើមិនបេះពាក្យស្រួលខ្យល់ “រ” មិញ
ឲ្យដេកវិញជាជាងកុំតែងឡើយ ។
មួយបើអ្នកឯណាចង់ចម្លង
តាមទំនងនិពាសនេះលោកអើយ
ចូររាំងខ្យល់ “រ” “ល” ជាត្រើយ
តែបាត់ហើយខូចដល់ខ្ញុំអ្នកតែង ។
មួយស្រៈ “ ៃ ” បំភ្លៃទឹងស្រៈ “ ៊ ”
វិសជិនីយខ្យល់ “ស” លោកសម្តែង

កុំឲ្យចូលយារមុខទន្គុកឯង
ឲ្យនៅតាមកន្លែងទីដោយខ្លួន ។
ពាក្យសំយោគការន្តវិធីសត្ថ
ចូលលំដាប់ព៉ប់គ្នាទៅតាមផ្ទួន
យោគសេចក្តីតាំងមុខឲ្យមាំមួន
រកចុងជួនមេកាព្យសភាពអើយ ។

ចប់

តម្លៃ : ៣.០០០ រៀល

រោងពុម្ព មានជ័យ